# អានាបានស្សតិ

រៀបរៀងដោយ

**ភិក្ខុ ខិន តេន ឥន្ទបញ្ញោ**

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

ដោយ

ឧបាសក តាន់ ណាំ
ឧបាសិកា លឹម ឆេងអ៊ី

# អានាបានស្សតិ

រៀបរៀងដោយ

ភិក្ខុ ខិន ភេន ឥន្ទបញ្ញោ

វាយកុំព្យូទ័រដោយ

ភិក្ខុ ពេជ្រ សាម៉ុន ចិរវឌ្ឍោ

បោះពុម្ពចែកជាធម្មទាន

ចំនួន ១៥០០ ក្បាល

ឧបត្ថម្ភដោយ

វត្តពោធិវង្ស ប្រទេសបារាំង

ព.ស. ២៥៥៣ គ.ស. ២០១០

# អារម្ភកថា

៙៚

ឧបាសិកា លិម ឆេងអ៊ី និង ឧបាសក តាន់ ណាំ បានយកបច្ច័យ ១០០០ € មកប្រគេន សុំឲ្យជួយរៀបរៀងបោះពុម្ពសៀវភៅធម៌មួយ ចែកជាធម្មទាន ។ ខ្ញុំ អាត្មា សួរថា ញោមចង់បានធម៌អ្វី ? គាត់ឆ្លើយថា ខ្ញុំព្រះករុណា មានសទ្ធាជ្រះថ្លា ចូលចិត្តបដិបត្តិធម៌... ។

អាស្រ័យហេតុប៉ុណ្ណេះជាដើម ខ្ញុំ អាត្មា នឹកគិតថា អានាបានស្សតិ គេចូលចិត្ត សិក្សាបដិបត្តិច្រើន ទើបសម្រេចរៀបរៀងកូនសៀវភៅ អានាបានស្សតិ ឡើង ។ ខ្ញុំ អាត្មា សង្ឃឹមថាកូនសៀវភៅនេះ នឹងជួយបំភ្លឺលោក អ្នក មានសទ្ធាជ្រះថ្លា ក្នុងផ្លូវសិក្សាបដិបត្តិតាមព្រះពុទ្ធសាសនា បានខ្លះជាពុំខាន។

សូមវិញ្ញាណបុព្វការីជន និង ពួកញាតិ នៃ ឧបាសិកា លិម ឆេងអ៊ី និង ឧបាសក តាន់ ណាំ អនុមោទនា ទទួលយកនូវឥដ្ឋមនុញ្ញផល នៃ ធម្មទាននេះ កុំបីខាន ។

សូមផលនៃធម្មទាននេះ បានជាពលវប្បច្ច័យ ជួយញោមទាំងពីររូប និងកូនចៅ បានជួប ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ និង បានប្រកបដោយ សេចក្ដីសុខ ចំរើន រៀងរាបដរាបដល់បានសម្រេចព្រះនិព្វាន ជាបរិយោសាន កុំបីអាក់ខានឡើយ ។៚

វត្តពោធិវង្ស ប្រទេសបារាំង

ថ្ងៃពុធ ៦ ឧសភា ២០០៩

ភិក្ខុ ធិន ភេន ឥន្ទប្បញ្ញោ

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# អានាបានស្សតិ សូត្រ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់ ឧបាសិកា វិសាខាមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ជាមួយនឹងសាវក ជាថេរៈ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញគឺ : ព្រះសារីបុត្ត ព្រះមហាមោគ្គល្លាន ព្រះមហាកស្សប ព្រះមហាកច្ចាយនៈ ព្រះមហាកោដ្ឋិតៈ ព្រះមហាកប្បិន ព្រះមហាចុន្ទ ព្រះរេវតៈ និង ព្រះអានន្ទ ព្រមទាំង ព្រះថេរៈឯទៀតជាច្រើន ។

សម័យនោះឯង ព្រះថេរៈទាំងឡាយ តែងទូន្មានប្រៀនប្រដៅភិក្ខុថ្មី ។ ១០ រូបក៏មាន ២០ រូបក៏មាន ៣០ រូបក៏មាន ៤០ រូបក៏មាន ។ ភិក្ខុថ្មីអម្បាលនោះ ក៏បានចេះដឹងធម៌វិសេសច្រើនឡើងជាងពីពេលមុន ។

សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាលស្រឡះ នាថ្ងៃពេញបូណ៌មី រាត្រីព្រះចន្ទពេញវង់ ជាថ្ងៃបវារណា ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៅកាន់ភិក្ខុសង្ឃ ដែលគង់ស្ងាត់ស្ងៀមថា ម្នាលភិក្ខុទាំងឡាយ តថាគត ប្រារព្ធចំពោះបដិបទានេះ តថាគត មានចិត្តត្រេកអរចំពោះបដិបទានេះ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រារព្ធសេចក្តីព្យាយាមឲ្យលើសជាងប្រមាណចុះ ដើម្បីឲ្យដល់ធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីឲ្យសម្រេចធម៌ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ តថាគត នឹងរង់ចាំអ្នកទាំងឡាយ ក្នុងក្រុងសាវត្ថីនេះឯង រហូតដល់ ៤ ខែ ជាកាលរីកនៃផ្កាកុមុទ (គឺពេញបូណ៌មីខែកត្តិក) ។

វកកម្មដ្ឋាន ។ ភិក្ខុនោះ មានស្មារតី ដកដង្ហើមចូល មានស្មារតី ដកដង្ហើមចេញ ។

១-កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី។

៣-ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ (គឺខ្យល់ដកដង្ហើម) ទាំងពួង ដកដង្ហើមចូល សិក្សាថា អាត្មាអញដឹងច្បាស់ នូវកាយ ទាំងពួង ដកដង្ហើមចេញ ។

៤-ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ (គឺខ្យល់ដក-ដង្ហើម) ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដក-ដង្ហើមចេញ ។

៥-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ ។

៦-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចេញ ។

៧-ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ (គឺវេទនា និងសញ្ញា) ដកដង្ហើមចូល សិក្សាថា អាត្មាអញដឹងច្បាស់ចិត្តសង្ខារ ដកដង្ហើមចេញ ។

៨-ភិក្ខុសិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ (ដែលគ្រោតគ្រាត) ដកដង្ហើមចូល សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ ។

៩-ភិក្ខុសិក្សាថា អាត្មាអញនឹងច្បាស់នូវចិត្ត ដកដង្ហើមចូល សិក្សាថា អាត្មាអញនឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ ។

១០-ភិក្ខុសិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចេញ ។

១១-ភិក្ខុសិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ (ក្នុងអារម្មណ៍) ដកដង្ហើមចូល សិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ ដកដង្ហើមចេញ ។

១២-ភិក្ខុសិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចេញ ។

១៣-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ញក្ខន្ធថាមិនទៀង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ញក្ខន្ធថាមិនទៀង ដកដង្ហើមចេញ ។

១៤-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចេញ ។

១៥-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចេញ ។

១៦-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់

បោលនូវកិលេស ដកដង្ហើមចេញ [១] ។

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនហើយ ។ ហើយយ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។

❀❀❀

## ចំរើន អានាបានស្សតិ ដូចម្តេច ញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌បាន

ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនហើយ ។ ដូចម្តេច ទើបញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌បាន។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង, កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី, សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង

---

[១]- ក្នុងគម្ពីរ មិនមានដាក់លេខទេ ប៉ុន្តែ ខ្ញុំដាក់លេខ ដើម្បីងាយចំណាំ ។ អានាបានស្សតិ មានវត្ថុ ១៦ គឺមានរឿង ១៦ ចំណុចដែលគេត្រូវសិក្សាតាមលំដាប់លេខដែលខ្ញុំបានដាក់ហើយនេះ ។ ពីលេខ ១ ដល់លេខ ៤ ជាកាយានុបស្សនា, ពីលេខ ៥ ដល់លេខ ៨ ជាវេទនានុបស្សនា, ពីលេខ ៩ ដល់លេខ ១២ ជាចិត្តានុបស្សនា, ពីលេខ ១៣ ដល់លេខ ១៦ ជាធម្មានុបស្សនា ។ អ្នកបដិបត្តិ ត្រូវសិក្សាបដិបត្តិឲ្យគ្រប់ទាំង ១៦ ចំណុចនេះ ទើបបានសម្រេចផលច្រើន ។

ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ, ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ ជាអ្នកមានព្យាយាមដុតកិលេស (អាតាបី) ជាអ្នកមានសម្បជញ្ញៈ ដឹងខ្លួនសព្វ (សម្បជានោ) ជាអ្នកមានសតិកំណត់ (សតិមា) កំចាត់បង់នូវអភិជ្ឈា និង ទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ជាកាយមួយក្នុងបណ្តាកាយទាំងឡាយ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ ជាអ្នកមានព្យាយាម[២] មានសម្បជញ្ញៈ មានសតិ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ រម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ, ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ពិចារណាឃើញរឿយ ៗ

---

[២]- ប្រែកាត់ខ្លី ។

នូវវេទនាក្នុងវេទនាទាំងឡាយ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមានសម្បជញ្ញៈដឹងខ្លួនសព្វ ជាអ្នកមានសតិកំណត់ កំចាត់បង់ នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគត ពោលថា ការធ្វើទុកក្នុងចិត្តនូវខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ បានល្អនេះ ជាវេទនាមួយ ក្នុងបណ្ដាវេទនាទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ ជាអ្នកមានព្យាយាម មានសម្បជញ្ញៈ មានសតិ កំចាត់បង់នូវ អភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ ដកដង្ហើមចូល សិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចេញ, ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមានសម្បជញ្ញៈ ដឹងខ្លួនសព្វ ជាអ្នកមានសតិកំណត់ កំចាត់បង់នូវ អភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលថា មានការចំរើនអានាបានស្សតិ របស់បុគ្គលអ្នកអត់សតិ អ្នកអត់សម្បជញ្ញៈ ទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវចិត្តក្នុងចិត្ត ជាអ្នកមានព្យាយាម មានសម្បជញ្ញៈ មានសតិ កំចាត់

បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ចក្ខន្ធថាមិនទៀង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ចក្ខន្ធថាមិនទៀង ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចេញ, សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចេញ, ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ពិចារណា ឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមាន សម្បជញ្ញៈ ដឹងខ្លួនសព្វ ជាអ្នកមានសតិកំណត់ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។ ភិក្ខុនោះ បានឃើញដោយបញ្ញា នូវការលះបង់ នូវអភិជ្ឈា និង ទោមនស្ស ហើយព្រងើយកន្តើយ ដោយប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាម មានសម្បជញ្ញៈ មានសតិ កំចាត់បង់ នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចំរើនហើយ យ៉ាងនេះ បានធ្វើឲ្យច្រើនរឿយ ៗ ហើយយ៉ាងនេះ រមែងញុំាងសតិប្បដ្ឋាន ៤ ឲ្យពេញបរិបូណ៌បាន ។

## ចំរើន សតិប្បដ្ឋាន៤ ដូចម្តេច
## ទើបញ៉ាំង ពោជ្ឈង្គ៧ ឲ្យពេញបរិបូណ៌បាន

ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ បុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនរឿយ ៗ ដូចម្តេច ទើបញ៉ាំងពោជ្ឈង្គ ៧ ឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមានសម្បជញ្ញៈដឹងខ្លួនសព្វ ជាអ្នកមានសតិកំណត់ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ សតិ រមែងជាធម្មជាតដែលភិក្ខុចូលទៅតម្កល់ទុកមាំហើយ មិនភ្លេចភ្លាំង ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា សតិ ដែលភិក្ខុចូលទៅតម្កល់ទុកមាំហើយ មិនភ្លេចភ្លាំង ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ សម័យនោះ ភិក្ខុឈ្មោះថា ចំរើនសតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ ភិក្ខុនោះ មានសតិដូចនោះ ក៏ស្រាវជ្រាវ ត្រិះរិះ ពិចារណាធម៌នោះ ដោយបញ្ញា ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានសតិដូចនោះ ស្រាវជ្រាវ ត្រិះរិះ ពិចារណាធម៌នោះ ដោយបញ្ញា ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ សម័យនោះ ភិក្ខុឈ្មោះថា ចំរើនធម្មវិចយសម្ពោជ្ឈង្គ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ ភិក្ខុនោះ ស្រាវជ្រាវ ត្រិះរិះ

ពិចារណាធម៌ ដោយបញ្ញា រមែងប្រារព្ធព្យាយាម មិនធូរថយ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុស្រាវជ្រាវ ត្រិះរិះ ពិចារណាធម៌នោះ ដោយបញ្ញា ប្រារព្ធព្យាយាម មិនធូរថយ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ចំរើនវីរិយសម្ពោជ្ឈង្គ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ បីតិ ដែលប្រាសចាកអាមិស ក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាកអាមិស កើតឡើងដល់ភិក្ខុ ដែលប្រារព្ធព្យាយាមហើយ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ចំរើនបីតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ កាយក្តី ចិត្តក្តី របស់ភិក្ខុ ដែលមានចិត្តប្រកបដោយបីតិ រមែងស្ងប់រម្ងាប់ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា កាយក្តី ចិត្តក្តី របស់ភិក្ខុ ដែលមានចិត្តប្រកបដោយបីតិ ស្ងប់រម្ងាប់ហើយ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ ចិត្តរបស់ភិក្ខុ ដែលមានកាយស្ងប់រម្ងាប់ មានសេចក្តីសុខ រមែងតាំងនៅមាំ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុ ដែលមានកាយស្ងប់រម្ងាប់ មានសេចក្តីសុខ តាំងនៅមាំ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ចំរើនសមាធិសម្ពោជ្ឈង្គ

ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ ភិក្ខុនោះ រមែងជាអ្នកញុំាងចិត្តដែលតាំងនៅមាំដូចនោះ ឲ្យព្រងើយកន្តើយ ដោយប្រពៃ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅមាំដូចនោះ ឲ្យព្រងើយកន្តើយ ដោយប្រពៃ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាចំរើន ឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុពិចារណាឃើញរឿយ ៗ នូវវេទនា ក្នុង វេទនាទាំងឡាយ... នូវចិត្តក្នុងចិត្ត... នូវធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមានសម្បជញ្ញៈដឹងខ្លួនសព្វ ជាអ្នកមានសតិកំណត់ កំចាត់បង់នូវអភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ក្នុងសម័យនោះ សតិ រមែងជាធម្មជាតដែលភិក្ខុចូលទៅតម្កល់ទុកមាំហើយ មិនភ្លេចភ្លាំង ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ សតិ ដែលភិក្ខុចូលទៅតម្កល់ទុកមាំហើយ មិនភ្លេចភ្លាំង ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ សម័យនោះ ភិក្ខុឈ្មោះថា ចំរើនសតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ក៏ដល់កិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។ ភិក្ខុនោះ មានសតិដូចនោះ ក៏ស្រាវជ្រាវ ត្រិះរិះ ពិចារណាធម៌នោះ ដោយបញ្ញា ។

។ល។ វេទនា ចិត្ត ធម៌ គេត្រូវពិចារណាដូចគ្នា និង កាយ ដែរ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅមាំ

ដូចនោះ ឲ្យព្រងើយកន្តើយ ដោយប្រពៃ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើននៃភិក្ខុ ។

ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនរឿយ ។ ហើយយ៉ាងនេះ រមែងញ៉ាំងពោជ្ឈង្គ ៧ ឲ្យពេញបរិបូណ៌បាន ។

## ចំរើន ពោជ្ឈង្គ ៧ ដូចម្តេច
## ទើបញ៉ាំង វិជ្ជា និង វិមុត្តិ ឲ្យពេញបរិបូណ៌បាន

ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យច្រើនរឿយ ។ ដូចម្តេច ទើបញ៉ាំងវិជ្ជា និង វិមុត្តិ ឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ ជាធម្មជាតបង្អោនចិត្តទៅដើម្បីលះបង់ ។ ភិក្ខុចំរើន ធម្មវិចយសម្ពោជ្ឈង្គ... ចំរើន វីរិយសម្ពោជ្ឈង្គ... ចំរើន បីតិសម្ពោជ្ឈង្គ... ចំរើន បស្សទ្ធិសម្ពោជ្ឈង្គ... ចំរើន សមាធិ-សម្ពោជ្ឈង្គ... ចំរើន ឧបេក្ខាសម្ពោជ្ឈង្គ... ដែលអាស្រ័យវិវេក អាស្រ័យវិរាគ អាស្រ័យនិរោធ ជាធម្មជាតបង្អោនចិត្តទៅដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គ ៧ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនរឿយ ។ ហើយ យ៉ាងនេះ រមែងញ៉ាំងវិជ្ជា និង វិមុត្តិ ឲ្យពេញបរិបូណ៌បាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងនូវ អានាបានស្សតិ សូត្រនេះចប់ហើយ

ភិក្ខុទាំងឡាយនោះ មាចិត្តត្រេកអរ រីករាយចំពោះភាសិត នៃ ព្រះមាន
ព្រះភាគ[៣] ។៚

ចប់ អានាបានស្សតិសូត្រ

## សង្ខេប និង បដិបត្តិ

៚*៚

១-មុននឹងសម្តែង អានាបានស្សតិ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត ប្រារព្ធបដិបទានេះ ។ អ្នកទាំងឡាយ ចូរប្រារព្ធព្យាយាមឲ្យច្រើន ដើម្បីឲ្យដល់ធម៌ដែលខ្លួនមិនទាន់បានដល់ ។ ក្នុងភិក្ខុសង្ឃនេះ មានភិក្ខុជាព្រះអរហន្ត មានភិក្ខុជាអនាគាមី មានភិក្ខុជាសកទាគាមី មានភិក្ខុជាសោតាបន្ន មានភិក្ខុអ្នកចំរើន សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គមានអង្គ ៨ មានភិក្ខុអ្នកចំរើន មេត្តា ករុណា មុទិតា ឧបេក្ខា មានភិក្ខុអ្នកចំរើន អសុភ និង អនិច្ចសញ្ញា ។

ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានភិក្ខុអ្នកចំរើន អានាបានស្សតិ ។ អានាបានស្សតិ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។

ពុទ្ធដីកានេះ ហាក់ដូចជាបញ្ជាក់ថា អានាបានស្សតិ មានផលច្រើន មានអានិសង្សច្រើន ពិតមែន ប៉ុន្តែ ត្រូវមានធម៌ដែលព្រះអង្គបានសម្តែងទុកខាងដើមនោះ ចូលរួមផ្សំផង បើមិនដូចនោះទេ មិនអាចសម្រេចផលច្រើន

---

(៣)- សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសក ២៦ / ២៨២ / ៣៥២

បានឡើយ ។ ហេតុនេះ អ្នកស្វែងរកធម៌ ត្រូវតែបដិបត្តិតាមគោលធម៌ដែលព្រះអង្គបានសម្តែងទុកខាងដើមនោះ ជាការចាំបាច់ ។

២-អានាបានស្សតិ ដែលគេធ្វើខុសទំនង មិនអាចមានផលច្រើន មានអានិសង្សច្រើនបានទេ ។ អានាបានស្សតិ ដែលមានផលច្រើន មានអានិសង្សច្រើននោះ ត្រូវប្រកបដោយវត្ថុ ១៦ គឺ គេដកដង្ហើម ១៦ ចំណុច ចេញទៅជាសតិប្បដ្ឋាន ៤ បានសេចក្តីថា គេដឹងច្បាស់នូវ កាយ វេទនា ចិត្ត ធម៌ ក្នុងពេលដកដង្ហើមនោះ ។ គេចំរើន សតិប្បដ្ឋាន ៤ នោះ ឲ្យច្រើនរឿយ ៗ ហើយ ពោជ្ឈង្គ ៧ ក៏កើតពេញបរិបូណ៌បាន ។ គេចំរើន ពោជ្ឈង្គ ៧ នោះ ឲ្យច្រើនរឿយ ៗ ហើយ វិជ្ជា និង វិមុត្តិ ក៏កើតពេញបរិបូណ៌បាន ។ អានាបានស្សតិ ដែលគេចំរើនយ៉ាងនេះ ដែលគេធ្វើឲ្យច្រើនរឿយ ៗ ហើយយ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។

***<u>កំណត់សំគាល់</u>*** - ក្នុងពេលដកដង្ហើម ចំណុចណា បើគេមិនទាន់មាន ដូច បីតិ ឬ សុខៈ ជាដើម គេត្រូវយកសុខវេទនា ឬ ទុក្ខវេទនា ធម្មតាដែលកំពុងប្រាដកមកជំនួស ។ ចំណែកចិត្ត ក៏មានអត្ថន័យ ដូចគ្នា ដែរ ។

៣-វិវេក ៥ គឺ :

១-វិក្ខម្ភនវិវេក ការស្ងាត់នីវរណធម៌ ដោយការសង្កត់ទុក របស់អ្នកចំរើនសមាធិ ។

២-តទង្គវិវេក ការស្ងាត់ទិដ្ឋិ ដោយអង្គធម៌ផ្ទុយគ្នា ដូចស្ងាត់ សក្កាយទិដ្ឋិ ដោយកំណត់នាមរូប របស់អ្នកវិបស្សនា ។

៣-សមុច្ឆេទវិវេក ការស្ងាត់កិលេសដោយដាច់ខាត ក្នុងខណៈនៃលោកុត្តរមគ្គ ។

៤-បដិបស្សទ្ធិវិវេក ការស្ងាត់កិលេសដោយដាច់ខាត ក្នុងខណៈនៃ

លោកុត្តរផល ។

៥-និស្សរណវិវេក ការស្ងាត់សង្ខតធម៌ (បន្ទាប់ពីលោកុត្តរផល) គឺ អមតនិព្វាន ។

វិរាគ ៥ និរោធ ៥ វោស្សគ្គ ៥ (បហានៈ ៥) មានអត្ថន័យដូចគ្នា ។

អ្នកចំរើនធម៌ មានសតិសម្ពោជ្ឈង្គ ជាដើម ត្រូវប្រកបដោយធម៌ ៣ យ៉ាងគឺ : ឆន្ទៈ សេចក្តីពេញចិត្ត ១ សទ្ធា សេចក្តីជ្រះថ្លាជឿស៊ប់ ១ សមាធិ ចិត្តតាំងមាំ ១ ដើម្បីស្ងាត់(អស់)កិលេស ទើបលោកពោលថា វិវេកនិស្សិតំ អាស្រ័យវិវេក វិរាគនិស្សិតំ អាស្រ័យវិរាគ និរោធនិស្សិតំ អាស្រ័យនិរោធ វោស្សគ្គបរិណាមឹ បង្អោនទៅដើម្បីលះបង់ មិនមែនបដិបត្តិធម៌ ដើម្បីអ្វីផ្សេងក្រៅពីនេះទេ ។

៤-អានាបានស្សតិ ដែលគេបដិបត្តិសព្វថ្ងៃនេះ ភាគច្រើន គេបដិបត្តិតាមគ្រូ តាមអាចារ្យរបស់គេ ។ ពួកខ្លះ គេរាប់ខ្យល់ដកដង្ហើមចូលចេញ, ពួកខ្លះ គេកំណត់ ពុទ្ធោ, ពួកខ្លះ គេកំណត់ ប៉ោង ផត, ពួកខ្លះ គេសង្កេតមើលវេទនា, ពួកខ្លះ គេកំណត់ថា មានដួងកែវភ្លឺថ្លានៅក្នុងខ្លួនរបស់គេលើផ្ចិត..។ល។ គ្រូអាចារ្យខ្លះ ចូលចិត្តអួត... សិស្សខ្លះ ក៏អួតដែរខំអួតបន្ថែមថា វិធីបដិបត្តិរបស់ពួកខ្លួន ជាធម៌ពិត ជាធម៌បរិសុទ្ធ ជាធម៌ដែលព្រះអរហន្តគ្រប់ព្រះអង្គ លោកបដិបត្តិតាមវិធីនេះ... ។ មិនត្រឹមតែប៉ុណ្ណោះ បុគ្គលខ្លះ លើកខ្លួន សង្កត់អ្នកដទៃ... ត្រង់ចំណុចនេះ រឹតតែមិនល្អ ។

ការបដិបត្តិតាមគ្រូអាចារ្យ មិនទាស់ខុសអ្វីទេ បើលោកគ្រូ អាចារ្យបានប្រើបញ្ញាម៉ត់ចត់ត្រឹមត្រូវហើយ ប៉ុន្តែ គេមិនត្រូវខំអួតហួសពេកទេ... ហើយក៏កុំភ្លេចយកធម៌ដែលព្រះពុទ្ធសម្តែងទុកហើយនោះ មកផ្ទៀងផ្ទាត់ និងបដិបត្តិ រួមផ្សំជាមួយគ្នាផង ៕

# មហារាហុលោវាទសូត្រ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ ចំណែក ព្រះរាហុល ក៏ប្រដាប់បាត្រចីវរ ដើរតាមក្រោយ ៗ ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ឆ្លៀងព្រះភក្ត្រ ត្រាស់ទៅកាន់រាហុលថា ម្នាលរាហុល រូបឯណានីមួយ ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ជាអតីត អនាគត បច្ចុប្បន្នក្តី រូបទាំងអស់នោះ គ្រាន់តែជារូប អ្នកគប្បីឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត ដូចនេះ ទុំះ មិនមែនរបស់អញ អញមិនមែនជាទុំះ ទុំះ មិនមែនជាខ្លួនរបស់អញ ។ ព្រះរាហុល ក្រាបបង្គំទូលសួរថា បពិត្រព្រះមានព្រះភាគ ចំពោះតែរូបមួយទេឬ ? ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ទាំងរូប ទាំងវេទនា ទាំងសញ្ញា ទាំងសង្ខារ ទាំងវិញ្ញាណដូចគ្នា ។

គ្រានោះឯង ព្រះរាហុល គិតថា ថ្ងៃនេះ នរណាហ្ន៎ ដែលព្រះមានព្រះភាគ ទ្រង់ប្រទានឱវាទផ្ទាល់ ហើយនឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតដូចនេះ លោកក៏ត្រឡប់ថយក្រោយ ហើយចូលទៅគង់ពត់ភ្នែន តម្រង់កាយឲ្យត្រង់ តម្កល់ស្មារតី ឆ្ពោះទៅរកកម្មដ្ឋាន ទៀបគល់ឈើ ១ ដើម ។ គាប់ចួន ព្រះសារីបុត្ត បានឃើញព្រះរាហុល កំពុងអង្គុយពត់ភ្នែន ក៏ប្រាប់ឲ្យចំរើន អានាបានស្សតិ ម្នាលរាហុល ព្រោះថា អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងមានផលច្រើន មាន

អានិសង្សច្រើន ។ លុះដល់ពេលរសៀល ព្រះរាហុលចេញពីកម្មដ្ឋាន ចូលទៅគាល់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរ ហើយក្រាបទូលសួរថា បពិត្រព្រះមានព្រះភាគ អានាបានស្សតិ ដែលបុគ្គលចំរើនហើយដូចម្តេច ធ្វើឲ្យច្រើនរឿយ ៗ ហើយដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។

## ធាតុ ៥

១-ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលរាហុល រូបឯណានីមួយ ជារូបខាងក្នុង អាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ដែលវិញ្ញាណកាន់កាប់ គឺ : សក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ពុំនោះសោត រូបឯណានីមួយ ក្រៅអំពីនេះ ជារូបខាងក្នុង អាស្រ័យនូវខ្លួន ជារូបគ្រោតគ្រាត ជារូបរឹង ដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះហៅថា បឋវីធាតុខាងក្នុង ។ ក៏បឋវីធាតុខាងក្នុងក្តី បឋវីធាតុខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា បឋវីធាតុដូចគ្នា ។ អ្នកគប្បីឃើញនូវបឋវីធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ព្រោះបុគ្គលឃើញនូវបឋវីធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយក្នុងបឋវីធាតុ រមែងញុំាងចិត្តឲ្យប្រាសចាកតម្រេក ក្នុងបឋវីធាតុ ។

២-ម្នាលរាហុល ចុះអាបោធាតុ តើដូចម្តេច អាបោធាតុ ខាងក្នុងក៏មាន អាបោធាតុខាងក្រៅក៏មាន ។ ម្នាលរាហុល អាបោធាតុខាងក្នុង តើដូចម្តេច រូបណាដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ដល់នូវភាពជាទឹក

ដែលវិញ្ញាណកាន់កាប់ គឺ : ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ពុំនោះសោត រូបឯណានីមួយ ក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាទឹក ដល់នូវភាពជាទឹក ដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះ ហៅថា អាបោធាតុខាងក្នុង ។ ក៏អាបោធាតុខាងក្នុងក្តី អាបោធាតុខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា អាបោធាតុ ដូចគ្នា ។ អ្នកគប្បីឃើញនូវអាបោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះ មិនមែនជាខ្លួនរបស់អញ ។ ព្រោះ បុគ្គលឃើញនូវអាបោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយក្នុងអាបោធាតុ រមែងញុំាងចិត្តឲ្យប្រាសចាកតម្រេក ក្នុងអាបោធាតុ ។

៣-ម្នាលរាហុល ចុះ តេជោធាតុ តើដូចម្តេច តេជោធាតុខាងក្នុងក៏មាន តេជោធាតុខាងក្រៅក៏មាន ។ ម្នាលរាហុល តេជោធាតុខាងក្នុង តើដូចម្តេច រូបណា ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវភាពជារបស់ក្តៅ ដែលវិញ្ញាណកាន់កាប់ គឺ : ភ្លើងដែលធ្វើកាយឲ្យក្តៅអប់ឧណ្ហ ភ្លើងដែលធ្វើកាយឲ្យទ្រុឌទ្រោម ភ្លើងដែលធ្វើកាយឲ្យក្តៅក្រហល់ក្រហាយ ភ្លើងដែលធ្វើអាហារដែល ស៊ី ផឹក ទំពា លិទ្ធភ្លក្ស ហើយឲ្យទ្រោមរលួយទៅដោយស្រួល ពុំនោះសោត រូបឯណានីមួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជារបស់ក្តៅ ដល់នូវភាពជារបស់ក្តៅ ដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះ ហៅថា តេជោធាតុខាងក្នុង ។ ក៏ តេជោធាតុខាងក្នុងក្តី តេជោធាតុខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា តេជោធាតុ ដូចគ្នា ។ អ្នកគប្បីឃើញនូវតេជោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះ

មិនមែនជាខ្លួនរបស់អញ ។ ព្រោះបុគ្គលឃើញនូវតេជោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយក្នុងតេជោធាតុ រមែងញ៉ាំងចិត្តឲ្យប្រាសចាកតម្រេក ក្នុងតេជោធាតុ ។

៤-ម្នាលរាហុល ចុះវាយោធាតុ តើដូចម្តេច វាយោធាតុខាងក្នុងក៏មាន វាយោធាតុខាងក្រៅក៏មាន ។ ម្នាលរាហុល វាយោធាតុខាងក្នុងតើដូចម្តេច រូបណាដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណកាន់កាប់ គឺ : ខ្យល់បក់ឡើងទៅខាងលើ ខ្យល់បក់ចុះមកខាងក្រោម ខ្យល់បក់ក្នុងពោះ ខ្យល់បក់ក្នុងពោះវៀន ខ្យល់បក់តាមអវយវៈតូចធំ ខ្យល់ដកដង្ហើមចូលចេញ ពុំនោះសោត ខ្យល់ឯណានីមួយ ក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាខ្យល់ ដល់នូវភាពជាខ្យល់ ដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះ ហៅថា វាយោធាតុខាងក្នុង ។ ក៏ វាយោធាតុខាងក្នុងក្តី វាយោធាតុខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា វាយោធាតុ ដូចគ្នា ។ អ្នកគប្បីឃើញនូវវាយោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះមិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ព្រោះបុគ្គលឃើញនូវវាយោធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះហើយ រមែងនឿយណាយ ក្នុងវាយោធាតុ រមែងញ៉ាំងចិត្តឲ្យប្រាសចាកតម្រេក ក្នុងវាយោធាតុ ។

៥-ម្នាលរាហុល អាកាសធាតុ តើដូចម្តេច អាកាសធាតុខាងក្នុងក៏មាន អាកាសធាតុខាងក្រៅក៏មាន ។ ម្នាលរាហុល អាកាសធាតុខាងក្នុងតើដូចម្តេច រូបណាដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាអាកាស ដល់នូវភាពជាទីវាលទំនេរ (ចន្លោះ ឬ ប្រហោង) ដែលវិញ្ញាណកាន់កាប់ គឺ : រន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ ប្រហោងបំពង់កសម្រាប់លេបនូវអាហារ ដែល

ស៊ី ផឹក ទំពា លិទ្ធភ្លក្ស ប្រហោងពោះសម្រាប់ទុកដាក់នូវអាហារដែលស៊ី... ប្រហោងពោះវៀនតូច ធំ សម្រាប់បញ្ចេញនូវអាហារដែល ស៊ី ផឹក ទំពា លិទ្ធភ្លក្ស មកតាមចំណែកខាងក្រោម ពុំនោះសោត រូបឯណានីមួយក្រៅអំពីនេះ ដែលជាខាងក្នុង អាស្រ័យនូវខ្លួន ជាអាកាស ដល់នូវភាពជាទីទំនេរ ជាទីទទេ ដល់នូវភាពទទេ ជាចន្លោះ ដល់នូវភាពជាចន្លោះ ដែលសាច់ និង ឈាមមិនប៉ះពាល់ ដែលវិញ្ញាណកាន់កាប់ ម្នាលរាហុល នេះហៅថា អាកាសធាតុខាងក្នុង ។ ក៏អាកាសធាតុខាងក្នុងក្តី អាកាសធាតុខាងក្រៅក្តី ធាតុទាំងនុ៎ះ ឈ្មោះថា អាកាសធាតុដូចគ្នា ។ អ្នកគប្បីឃើញនូវអាកាសធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិត យ៉ាងនេះថា នុ៎ះ មិនមែនរបស់អញ អញមិនមែនជានុ៎ះ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ ព្រោះបុគ្គលឃើញនូវអាកាសធាតុនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះហើយ រមែងនឿយណាយ ក្នុងអាកាសធាតុ រមែងញុំាងចិត្តឲ្យប្រាសចាកតម្រេក ក្នុងអាកាសធាតុ ។

## ភាវនាស្មើដោយធាតុ ៥

១-ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាផែនដី ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាផែនដីហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។ ម្នាលរាហុល ជនទាំងឡាយ តែងចោលនូវវត្ថុស្អាតក្តី វត្ថុមិនស្អាតក្តី គូថក្តី មូត្រក្តី ទឹកមាត់ក្តី ខ្ទុះក្តី ឈាមក្តី លើផែនដី ផែនដី មិននឿយណាយ មិនធុញទ្រាន់ ឬ មិនខ្ពើមរអើមដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាផែនដី យ៉ាងនោះឯង

ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាផែនដីហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

២-ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាទឹក ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាទឹកហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។ ម្នាលរាហុល ជនទាំងឡាយ លាងវត្ថុស្អាតក្តី លាងវត្ថុមិនស្អាតក្តី លាងគូថក្តី លាងមូត្រក្តី លាងទឹកមាត់ក្តី លាងខ្ទុះក្តី លាងឈាមក្តី ក្នុងទឹក ទឹកមិនធ្វើយណាយ មិនធុញទ្រាន់ ឬ មិនខ្ពើមរអើមដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាទឹកហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

៣-ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាភ្លើង ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។ ម្នាលរាហុល ភ្លើងរមែងឆេះវត្ថុស្អាតក្តី ឆេះវត្ថុមិនស្អាតក្តី ឆេះគូថក្តី ឆេះមូត្រក្តី ឆេះទឹកមាត់ក្តី ឆេះខ្ទុះក្តី ឆេះឈាមក្តី ភ្លើងមិនធ្វើយណាយ មិនធុញទ្រាន់ ឬ មិនខ្ពើមរអើមដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាភ្លើង យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាភ្លើងហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬមិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

៤-ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាខ្យល់ ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្ត-ឡើយ ។ ម្នាលរាហុល ខ្យល់តែងបក់វត្ថុស្អាតក្តី បក់វត្ថុមិនស្អាតក្តី បក់គូថក្តី បក់មូត្រក្តី បក់ទឹកមាត់ក្តី បក់ខ្ទុះក្តី បក់ឈាមក្តី ខ្យល់មិនធឿយណាយ មិនធុញទ្រាន់ ឬ មិនខ្ពើមរអើមដោយវត្ថុនោះឡើយ យ៉ាងណាមិញ ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាខ្យល់ យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាខ្យល់ហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។

៥-ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាអាកាស ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាអាកាសហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។ ម្នាលរាហុល អាកាសមិនតាំងនៅក្នុងទីណាមួយ យ៉ាងណា-មិញ ម្នាលរាហុល អ្នកចូរចំរើនភាវនាឲ្យដូចជាអាកាស យ៉ាងនោះឯង ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនភាវនាឲ្យដូចជាអាកាសហើយ ផស្សៈទាំងឡាយ ជាទីគាប់ចិត្ត ឬ មិនគាប់ចិត្ត ដែលកើតឡើងហើយ រមែងមិនគ្របសង្កត់ចិត្តឡើយ ។៚

## ភាវនាទី ៦

១-ម្នាលរាហុល អ្នកចូរចំរើនមេត្តាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនមេត្តាភាវនាហើយ អ្នកនឹងលះព្យាបាទ បាន ។

២-ម្នាលរាហុល អ្នកចូរចំរើនករុណាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនករុណាភាវនាហើយ អ្នកនឹងលះវិហេសា បាន ។

៣-ម្នាលរាហុល អ្នកចូរចំរើនមុទិតាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនមុទិតាភាវនាហើយ អ្នកនឹងលះអរតិ បាន ។

៤-ម្នាលរាហុល អ្នកចូរចំរើនឧបេក្ខាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនឧបេក្ខាភាវនាហើយ អ្នកនឹងលះបដិឃ បាន ។

៥-ម្នាលរាហុល អ្នកចូរចំរើនអសុភភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនអសុភភាវនាហើយ អ្នកនឹងលះរាគ បាន ។

៦-ម្នាលរាហុល អ្នកចូរចំរើនអនិច្ចសញ្ញាភាវនា ម្នាលរាហុល ព្រោះថា កាលបើអ្នកចំរើនអនិច្ចសញ្ញាភាវនាហើយ អ្នកនឹងលះអស្មិមានះ បាន ។

## អានាបានស្សតិ ភាវនា

ម្នាលរាហុល អ្នកចូរចំរើនអានាបានស្សតិភាវនា ម្នាលរាហុល អានាបានស្សតិ ដែលអ្នកចំរើនហើយ ធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល អានាបានស្សតិ ដែលបុគ្គលបានចំរើន ដូចម្ដេច បានធ្វើឲ្យច្រើនរឿយ ៗ ហើយ ដូចម្ដេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅទៀបគល់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់ស្មារតី ឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះ មានស្មារតី

ដកដង្ហើមចូល មានស្មារតី ដកដង្ហើមចេញ ។

១-កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ។

៣-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ ។

៤-ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ ។

៥-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ ។

៦-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវសុខ ដកដង្ហើមចេញ ។

៧-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចេញ ។

៨-ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ ។

៩-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ ។

១០-ភិក្ខុសិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចេញ ។

១១-ភិក្ខុសិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ ដកដង្ហើមចូល សិក្សាថា អាត្មាអញ តាំងចិត្តឲ្យស្មើ ដកដង្ហើមចេញ ។

១២-ភិក្ខុសិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចូល សិក្សាថា អាត្មាអញ ធ្វើចិត្តឲ្យរួចចាកនីវរណធម៌ ដកដង្ហើមចេញ ។

១៣-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនទៀង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនទៀង ដកដង្ហើមចេញ ។

១៤-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការប្រាសចាកតម្រេក ដកដង្ហើមចេញ ។

១៥-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលត់កិលេស ដកដង្ហើមចេញ ។

១៦-ភិក្ខុសិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចូល សិក្សាថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចេញ ។

ម្នាលរាហុល អានាបានស្សតិ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនរឿយ ៗ ហើយយ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលរាហុល កាលបើ អានាបានស្សតិ ដែលបុគ្គលបានចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើនរឿយ ៗ ហើយយ៉ាងនេះ ខ្យល់ដកដង្ហើមចូល ខ្យល់ដកដង្ហើមចេញ ទាំងឡាយ ដែលមានក្នុងកាលជាខាងក្រោយ (**ចរិមកា អស្សាសបស្សាសា**) រមែងជាខ្យល់ដកដង្ហើម ដែលបុគ្គលអ្នកចំរើន

អានាបានស្សតិ ដឹងច្បាស់ហើយរលត់ទៅ មិនមែនមិនដឹងច្បាស់ហើយរលត់ទៅទេ ។ លុះព្រះមានព្រះភាគ សម្ដែងព្រះសូត្រនេះចប់ហើយ ព្រះរាហុល ដ៏មានអាយុ មានចិត្តត្រេកអរ រីករាយ ចំពោះភាសិត នៃ ព្រះមានព្រះភាគ[៤] ។ល។

ចប់ មហារាហុលសូត្រ

## សង្ខេប និង បដិបត្តិ

១-ព្រះពុទ្ធ សូម្បីក្នុងពេលកំពុងចេញទ្រង់បិណ្ឌបាត ក៏ឆ្លៀតសម្ដែងធម៌ប្រោសសត្វលោកដែរ ។

២-ព្រះរាហុល ពេលបានទទួលព្រះឱវាទផ្ទាល់ពីព្រះពុទ្ធយ៉ាងនេះ ក៏សម្រេចចិត្តមិនទៅបិណ្ឌបាត គឺ ឆាន់ធម៌ជំនួសភត្ត ។ នេះហើយ ចិត្តអ្នកស្វែងរកធម៌ ។

៣-ព្រះពុទ្ធ ពេលដែលព្រះរាហុល ទូលសួរថា អានាបានស្សតិ ដែលបុគ្គលចំរើនហើយ ដូចម្ដេច ធ្វើឲ្យច្រើនរឿយៗ ហើយ ដូចម្ដេច ទើបមានផលច្រើន មានអានិសង្សច្រើន ព្រះអង្គ មិនត្រាស់ អានាបានស្សតិ តបភ្លាមទេ ទ្រង់សម្ដែង ធាតុ ៥ ការបដិបត្តិស្មើដោយធាតុ ៥ និង ការភាវនាធម៌ ៦ ចប់ហើយ ទើបព្រះអង្គសម្ដែង អានាបានស្សតិ ជាក្រោយ ។ នេះបញ្ជាក់ថា ព្រះពុទ្ធ មានព្រះបំណងឲ្យសាវក បដិបត្តិគុណធម៌ឯទៀតរួមផ្សំផង ។ ព្រោះថា មនុស្សណាក៏ដោយ គេនឹងទៅជាអ្នកសម្រេច មគ្គ ផល ឬ គេនឹងទៅជាមនុស្សល្អម្នាក់បាន គេត្រូវប្រកបដោយគុណផ្សេងៗ ឯទៀតច្រើន

---

[៤]- សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក ២៣ / ១៣៣ / ២២៩

ណាស់ មិនមែនយករួចតែខ្លួនមួយ មិនមែនបដិបត្តិធម៌ហើយលែងដឹងអ្វី លែងទាក់ទងនឹងមនុស្សលោកនោះទេ ។

៤-ព្រះពុទ្ធ សម្តែងថា អានាបានស្សតិ ដែលបុគ្គលបានចំរើនល្អហើយ... គេនឹងមានសតិស្មារតី រឹងប៉ឹង ដឹងរហូតដល់ខ្យល់ដកដង្ហើមចូលចេញ ជាចុងក្រោយបំផុត ។

## ឥច្ឆានង្គលសូត្រ

សម័យនោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះ ឥច្ឆានង្គល ជិតក្រុងឥច្ឆានង្គល ។ ព្រះមានព្រះភាគ... ត្រាស់ហៅភិក្ខុទាំងឡាយមកថា បើពួកបរិព្វាជកជាអន្យតិរ្ថិយ សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម គង់ចាំវស្សាច្រើនដោយវិហារធម៌ដូចម្តេច ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីដោះស្រាយ... យ៉ាងនេះវិញថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគគង់ចាំវស្សាច្រើនដោយ អានាបានស្សតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគត មានស្មារតី ដកដង្ហើមចូល មានស្មារតី ដកដង្ហើមចេញ ។

១-កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ។

៣-តថាគត ដឹងច្បាស់ថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង

ដកដង្ហើមចូល ដឹងច្បាស់ថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ ។

៤-តថាគត ដឹងច្បាស់ថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល ដឹងច្បាស់ថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ ។ ។ល។

១៦-តថាគត ដឹងច្បាស់ថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចូល ដឹងច្បាស់ថា អាត្មាអញ ឃើញរឿយ ៗ នូវការរលាស់ចោលនូវកិលេស ដកដង្ហើមចេញ ។

ម្នាលភិក្ខុទាំងឡាយ បើពោលឲ្យត្រូវ បុគ្គលគប្បីពោលនូវ អានាបា-នស្សតិសមាធិ ថាជា អរិយវិហារ (ធម៌ជាគ្រឿងនៅរបស់ព្រះអរិយ) ក៏បាន ថាជា ព្រហ្មវិហារ (ធម៌ជាគ្រឿងនៅរបស់ព្រះព្រហ្ម) ក៏បាន ថាជា តថាគតវិហារ (ធម៌ជាគ្រឿងនៅរបស់ព្រះតថាគត) ក៏បាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាសេក្ខៈ មិនទាន់បានសម្រេចអរហត្តផលនៅឡើយ កាលបើប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈដ៏ប្រសើរ ភិក្ខុនោះ គប្បីចំរើន ធ្វើឲ្យច្រើនរឿយ ៗ នូវ អានាបានស្សតិសមាធិ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាជាព្រះអរហន្ត អស់កិលេសហើយ ភិក្ខុនោះ គប្បីចំរើន ធ្វើឲ្យច្រើនរឿយ ៗ នូវ អានាបានស្សតិសមាធិ ដើម្បីនៅជាសុខ ក្នុងបច្ចុប្បន្នផង ដើម្បី សតិ និង សម្បជញ្ញៈផង[២] ។

ចប់ ឥច្ឆានង្គលសូត្រ

---

[២]- សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៩ / ៦៤ / ៣៥

## សង្ខេប និង បដិបត្តិ

១-អានាបានស្សតិ ជាធម៌មួយដែលបុគ្គលចូលចិត្តបដិបត្តិច្រើន តាំងពីបូរាណកាលមក សូម្បីតែព្រះសម្មាសម្ពុទ្ធ បរមគ្រូយើង ព្រះអង្គ ក៏នៅច្រើនដោយ អានាបានស្សតិ ដែរ ។

២-អានាបានស្សតិ ជាធម៌មួយដែលបុគ្គលបដិបត្តិបានគ្រប់គ្នា មិនមែនចំពោះតែពួកបុថុជ្ជនទេ សូម្បីតែព្រះអរិយបុគ្គល ទាំងសេក្ខៈ ឬ អសេក្ខៈលោក ក៏នៅតែចំរើន អានាបានស្សតិ ដែរ ៕

## ទុតិយអានន្ទសូត្រ

គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ ធម៌ ១ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងញ៉ាំងធម៌ ៤ ឲ្យពេញបរិបូណ៌បាន, ធម៌ ៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងញ៉ាំងធម៌ ៧ ឲ្យពេញបរិបូណ៌បាន, ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងញ៉ាំងធម៌ ២ ឲ្យពេញបរិបូណ៌បាន មានដែរឬទេ ។ ព្រះអានន្ទ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយ របស់ទូលបង្គំយើងខ្ញុំ មានព្រះមានព្រះភាគជាមូល (ឫសគល់)... ។

ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ ធម៌ ១ នោះមាន គឺ អានាបានស្សតិ ។ ធម៌ ១ (គឺ អានាបានស្សតិ) ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងញ៉ាំងធម៌ ៤ (គឺ សតិប្បដ្ឋាន ៤) ឲ្យពេញបរិបូណ៌បាន, ធម៌៤ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ

រមែងញ៉ាំងធម៌ ៧ (គឺ ពោជ្ឈង្គ ៧) ឲ្យពេញបរិបូណ៌បាន, ធម៌ ៧ ដែលបុគ្គលបានចំរើន បានធ្វើឲ្យច្រើនរឿយ ៗ ហើយ រមែងញ៉ាំងធម៌ ២ (គឺ វិជ្ជា និងវិមុត្តិ) ឲ្យពេញបរិបូណ៌បាន[៣] ។

សេចក្តីអធិប្បាយ គប្បីយល់ដោយពិស្តារ
ដូចក្នុង អានាបានស្សតិសូត្រ ។

ចប់ ទុតិយអានន្ទសូត្រ

## ទីបសូត្រ

ម្នាលភិក្ខុទាំងឡាយ កាលមុនអំពីការត្រាស់ដឹង តថាគត នៅជាព្រះពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ តែងសម្រេចសម្រាន្តនៅច្រើនដោយវិហារធម៌ (អានាបានស្សតិ) នេះ ។ ម្នាលភិក្ខុទាំងឡាយ កាលតថាគត សម្រេចសម្រាន្តនៅច្រើនដោយវិហារធម៌នេះ កាយក៏មិនលំបាក ចក្ខុទាំងឡាយក៏មិនលំបាក ទាំងចិត្តរបស់តថាគត ក៏រួចចាកអាសវៈទាំងឡាយ មិនមានសេចក្តីប្រកាន់មាំ ។ ព្រោះហេតុនោះ -

១-បើភិក្ខុក្នុងសាសនានេះ ប៉ុនប៉ងថា កាយរបស់អាត្មាអញ កុំគប្បីលំបាក ចក្ខុទាំងឡាយរបស់អាត្មាអញ កុំគប្បីលំបាក ទាំងចិត្តរបស់អាត្មាអញ គប្បីរួចចាកអាសវៈទាំងឡាយ មិនមានសេចក្តីប្រកាន់មាំ ភិក្ខុ គប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវអានាបានស្សតិសមាធិ នេះចុះ ។

---

[៣]- សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៩ / ១០០ / ៥៤

២-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់មិនបដិកូល ថាបដិកូល ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវអានាបានស្សតិសមាធិ នេះចុះ ។

៣-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់បដិកូល ថាមិនបដិកូល ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវ អានាបា-នស្សតិសមាធិ នេះចុះ ។

៤-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់មិនបដិកូលផង បដិកូលផង ថាបដិកូល ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវអានាបានស្សតិសមាធិ នេះចុះ ។

៥-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកមានសេចក្តីសំគាល់ក្នុងរបស់បដិកូលផង មិនបដិកូលផង ថា មិនបដិកូល ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវ អានាបានស្សតិសមាធិ នេះចុះ ។

៦-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកវៀរនូវរបស់មិនបដិកូលផង បដិកូលផង ទាំងពីរនោះ ហើយព្រងើយកន្តើយ មានសតិ សម្បជញ្ញៈ ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវ អានាបានស្សតិសមាធិ នេះចុះ ។

៧-១៥-បើភិក្ខុ ប៉ុនប៉ងថា អាត្មាអញ គប្បីជាអ្នកបានសម្រេច បឋ-មជ្ឈាន ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន អាកាសានញ្ចាយតនជ្ឈាន វិញ្ញាណញ្ចាយតនជ្ឈាន អាកិញ្ចញ្ញាយតនជ្ឈាន នេវសញ្ញានាសញ្ញាយតនជ្ឈាន សញ្ញាវេទយិតនិរោធ ភិក្ខុគប្បីធ្វើទុកក្នុងចិត្តឲ្យប្រពៃ នូវ អានាបានស្សតិ-សមាធិ នេះចុះ ។

ម្នាលភិក្ខុទាំងឡាយ កាលបើ អានាបានស្សតិសមាធិ ដែលភិក្ខុបានចំរើន បានធ្វើឲ្យច្រើនរឿយៗ ហើយយ៉ាងនេះ បើភិក្ខុនោះសោយនូវវេទនា

ជាសុខ ដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា វេទនានោះ មិនគួរត្រេកអរ ដឹងច្បាស់ថា វេទនានោះ មិនគួររីករាយ ។ បើភិក្ខុនោះ សោយនូវវេទនាជាទុក្ខ ដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា វេទនានោះ មិនគួរត្រេកអរ ដឹងច្បាស់ថា វេទនានោះ មិនគួររីករាយ ។ បើភិក្ខុនោះ សោយនូវវេទនា មិនទុក្ខ មិនសុខ ដឹងច្បាស់ថា វេទនានោះមិនទៀង ដឹងច្បាស់ថា វេទនានោះ មិនគួរត្រេកអរ ដឹងច្បាស់ថា វេទនានោះ មិនគួររីករាយ ។ បើភិក្ខុនោះ សោយនូវវេទនាជាសុខ មានចិត្តមិនជាប់ជំពាក់ សោយនូវវេទនានោះ ។ បើភិក្ខុនោះ សោយនូវវេទនាជាទុក្ខ មានចិត្តមិនជាប់ជំពាក់ សោយនូវវេទនានោះ ។ បើភិក្ខុនោះ សោយនូវ វេទនា មិនទុក្ខ មិនសុខ មានចិត្តមិនជាប់ជំពាក់ សោយនូវវេទនានោះ ។ ភិក្ខុនោះ កាលសោយនូវវេទនា មានកាយជាទីបំផុត ដឹងច្បាស់ថា អាត្មាអញ សោយនូវវេទនា មានកាយជាទីបំផុត កាលសោយនូវវេទនា មានជីវិតជាទីបំផុត ដឹងច្បាស់ថា អាត្មាអញ សោយនូវវេទនា មានជីវិតជាទីបំផុត ដឹងច្បាស់ថា វេទនាទាំងពួងទាំងឡាយ ក្នុងលោកនេះ មិនគួររីករាយ នឹងរលត់ត្រជាក់ បន្ទាប់ពីបែកកាយ អស់ជីវិតទៅ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចប្រទីបប្រេង អាស្រ័យនូវប្រេង និង ប្រឆេះ គប្បីឆេះឡើងបាន ព្រោះអស់ប្រេង និង ប្រឆេះ មិនមានអាហារ (គ្រឿងធ្វើឲ្យឆេះ) គប្បីរលត់ទៅ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ កាលសោយនូវវេទនា មានកាយជាទីបំផុត ដឹងច្បាស់ថា អាត្មាអញ សោយនូវវេទនាមានកាយជាទីបំផុត កាលសោយនូវវេទនា មានជីវិតជាទីបំផុត ដឹងច្បាស់ថា អាត្មាអញ សោយនូវវេទនា មានជីវិតជាទីបំផុត ដឹងច្បាស់ថា វេទនាទាំងពួងទាំងឡាយ ក្នុងលោកនេះ មិនគួររីករាយ នឹងរលត់ត្រជាក់

បន្ទាប់ពីបែកកាយអស់ជីវិតទៅ ក៏យ៉ាងនោះដែរ[៤] ។

## សង្ខេត និង បដិបត្តិ

១-វត្ថុខ្លះ ដែលជាគោល (អារម្មណ៍) របស់កម្មដ្ឋាន ធ្វើឲ្យកាយពិបាករក ពិបាកទុកដាក់ ពិបាកយកតាមខ្លួន វត្ថុខ្លះ ធ្វើឲ្យភ្នែកពិបាកសម្លឹងចំណែក អានាបានស្សតិ អត់មានបញ្ហាអស់នេះ ទេ ។

២-ជាធម្មតា ពេលបានទទួលអារម្មណ៍ល្អ អភិជ្ឈា រមែងកើតឡើង ពេលបានទទួលអារម្មណ៍មិនល្អ ទោមនស្ស រមែងកើតឡើង ។ ទាំងពីរនេះ សុទ្ធតែជា កិលេស ។ ការហ្វឹកហាត់ប្រែអារម្មណ៍ មិនបដិកូល ឲ្យទៅជាបដិកូល... ជាដើម ជាឧបាយមួយល្អណាស់សំរាប់ទប់ រាគៈ ទោសៈ មោហៈ។

៣-កាលបើគេចំរើនធម៌ (អានាបានស្សតិ) បានល្អហើយ គេសោយសុខវេទនាក្តី ទុក្ខវេទនាក្តី អទុក្ខមសុខវេទនាក្តី គេជាអ្នកមានចិត្តមិនជាប់ជំពាក់ គឺ មិនមានអភិជ្ឈា ឬ ទោមនស្ស សោយនូវវេទនានោះ ។ បានសេចក្តីថា គេនៅមានវេទនា ដឹងសុខ ដឹងទុក្ខ ដឹងឆ្ងាញ់ ដឹងមិនឆ្ងាញ់ ដូចជាយើងដែរ តែគេមិនកើតកិលេស មិនមានបច្ច័យនៃតណ្ហា ៕

## មហាសតិប្បដ្ឋានសូត្រ

ក្នុងមហាសតិប្បដ្ឋានសូត្រ មានសម្តែងរឿង អានាបានស្សតិ ក្នុងពួកកាយ ត្រង់ អានាបានបព្វៈ មានសេចក្តីដូចតទៅនេះ :-

ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុពិចារណាឃើញនូវកាយក្នុងកាយជាប្រក្រតី

---

[៤]-សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៩ / ៣០ / ១៦

តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅទៀបគល់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់ស្មារតី ឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះ មានស្មារតី ដកដង្ហើមចូល មានស្មារតី ដកដង្ហើមចេញ ។

១-កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី។

៣-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ ។

៤-ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ ។

ម្នាលភិក្ខុទាំងឡាយ ជាងក្រឡឹងក្តី កូនសិស្សជាងក្រឡឹងក្តី ដែលប៉ិនប្រសប់ កាលទាញខ្សែក្រឡឹងវែង ក៏ដឹងច្បាស់ថា អាត្មាអញ ទាញខ្សែក្រឡឹងវែង កាលទាញខ្សែក្រឡឹងខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ទាញខ្សែក្រឡឹងខ្លី មានឧបមាដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

។ល។

សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ មានឧបមេយ្យដូច្នោះឯង។

ភិក្ខុពិចារណាឃើញនូវកាយ (ខ្យល់) ក្នុងកាយ ឮដ៏ខាងក្នុងជាប្រក្រតី ពិចារណាឃើញនូវកាយក្នុងកាយ ឮដ៏ខាងក្រៅជាប្រក្រតី ពិចារណាឃើញនូវកាយក្នុងកាយ ឮដ៏ខាងក្នុង និង ឮដ៏ខាងក្រៅជាប្រក្រតី ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយជាប្រក្រតី ពិចារណាឃើញនូវធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី ពិចារណាឃើញនូវធម៌ដែលប្រជុំកើតឡើងក្នុងកាយ និង ធម៌ដែលសូន្យទៅក្នុងកាយជាប្រក្រតី ។ ម្យ៉ាងទៀត សតិ របស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា កាយមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនគេ មិនមែនយើង...) គ្រាន់តែជាទីកំណត់ ដើម្បីឲ្យចំរើនប្រាជ្ញា ដើម្បីឲ្យចំរើនសតិប៉ុណ្ណោះ ។ ភិក្ខុ មានចិត្តមិនអាស្រ័យ (គឺមិនមានតណ្ហា និង ទិដ្ឋិ) មិនប្រកាន់(គឺមិនមានឧបាទាន) អ្វីតិចតួចក្នុងលោកឡើយ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ពិចារណានូវកាយក្នុងកាយជាប្រក្រតី យ៉ាងនេះឯង[៥] ។

## សង្ខេប និង បដិបត្តិ

អានាបានស្សតិ ក្នុងព្រះសូត្រនេះខ្លី ប៉ុន្តែ មានសេចក្តីចម្លែក គួរកត់សំគាល់ និង គប្បីសិក្សា ក្នុងមួយ ៗ ជា ៣ ចំណែក -

១-ឃើញនូវកាយ (ខ្យល់) ក្នុងកាយ (ក្នុងពួកកាយ) ឮដ៏ខាងក្នុង (កាយរបស់ខ្លួន) ។

២-ឃើញនូវកាយក្នុងកាយឮដ៏ខាងក្រៅ (កាយរបស់បុគ្គលដទៃ) ។

៣-ឃើញនូវកាយក្នុងកាយឮដ៏ខាងក្នុង និង ឮដ៏ខាងក្រៅ ។

---

[៥]- សុត្តន្តបិដក ទីឃនិកាយ មហាវារវគ្គ ១៧ / ១១២ / ២៤៦

១-ឃើញនូវធម៌ (ហេតុ) ប្រជុំកើតឡើងក្នុងកាយ (ខ្យល់ដង្ហើមចូល ចេញ + រន្ធច្រមុះ + ចិត្ត) ។

២-ឃើញនូវធម៌ (អស់ហេតុ) ដែលសូន្យទៅក្នុងកាយ (គឺអស់ខ្យល់ + រន្ធច្រមុះ + ចិត្ត) ។

៣-ឃើញនូវធម៌ប្រជុំកើតឡើងក្នុងកាយ និង ធម៌ដែលសូន្យទៅក្នុងកាយ ។

១-កាយមានមែន តែមិនមែនសត្វ មិនមែនបុគ្គល... គ្រាន់តែជាកាយ ។

២-មិនគួរមាន តណ្ហា ទិដ្ឋិ ក្នុងកាយ ។

៣-មិនគួរមាន ឧបាទាន ក្នុងកាយ ។ល។

## ភិក្ខុសូត្រ

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន... ។ គ្រានោះ ភិក្ខុ ១ រូប ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះអង្គ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គស្តាប់ធម៌ហើយ ជាបុគ្គលម្នាក់ឯង នឹងចេញទៅប្រឹងប្រែង បដិបត្តិធម៌... ។

ព្រះមានព្រះភាគ ត្រាស់ថា ព្រោះហេតុនោះ អ្នកចូរសំអាតធម៌ខាងដើមក្នុងកុសលធម៌ទាំងឡាយជាមុនសិន អ្វីធម៌ជាខាងដើមក្នុងកុសលធម៌ទាំងឡាយ គឺ សីល ស្អាត និង ទិដ្ឋិ ត្រង់ កាលបើសីលស្អាត ទិដ្ឋិត្រង់ហើយ អ្នកចូរអាស្រ័យសីល តាំងនៅក្នុងសីល ហើយគប្បីចំរើននូវ សតិប្បដ្ឋាន ៤

ដោយចំណែក ៣ ។ សតិប្បដ្ឋាន៤ តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ អ្នកចូរពិចារណាឃើញនូវកាយក្នុងកាយ ឰដីខាងក្នុងជាប្រក្រតី... ពិចារណាឃើញនូវកាយក្នុងកាយ ឰដីខាងក្រៅជាប្រក្រតី... ពិចារណាឃើញនូវកាយក្នុងកាយឰដីខាងក្នុង និង ឰដីខាងក្រៅជាប្រក្រតី... ជាអ្នកមានសេចក្តីព្យាយាម មានសតិ សម្បជញ្ញៈ ដើម្បីកំចាត់បង់នូវ អភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

អ្នកចូរពិចារណាឃើញនូវវេទនាក្នុងវេទនា ឰដីខាងក្នុងជាប្រក្រតី ពិចារណាឃើញនូវវេទនាក្នុងវេទនា ឰដីខាងក្រៅជាប្រក្រតី ។ល។

អ្នកចូរពិចារណាឃើញនូវចិត្តក្នុងចិត្ត ឰដីខាងក្នុងជាប្រក្រតី ពិចារណាឃើញនូវចិត្តក្នុងចិត្ត ឰដីខាងក្រៅជាប្រក្រតី ។ល។

អ្នកចូរពិចារណាឃើញនូវធម៌ក្នុងធម៌ ឰដីខាងក្នុងជាប្រក្រតី ពិចារណាឃើញនូវធម៌ក្នុងធម៌ ឰដីខាងក្រៅជាប្រក្រតី ។ល។ ជាអ្នកមានសេចក្តីព្យាយាម មានសតិ សម្បជញ្ញៈ ដើម្បីកំចាត់បង់នូវ អភិជ្ឈា និង ទោមនស្ស ក្នុងលោកចេញ ។

ម្នាលភិក្ខុ កាលណា អ្នកអាស្រ័យសីល តាំងនៅក្នុងសីលហើយ ចំរើន សតិប្បដ្ឋាន ៤ ដោយចំណែក ៣ កាលនោះ អ្នកគប្បីសង្ឃឹមសេចក្តីចំរើនក្នុងកុសលធម៌ទាំងឡាយ តែម្យ៉ាង ទាំងពេលយប់ ទាំងពេលថ្ងៃ ដែលនឹងមានមក សេចក្តីវិនាស នឹងមិនមានឡើយ ។

គ្រានោះ ភិក្ខុនោះ ត្រេកអររីករាយ ចំពោះភាសិត នៃ ព្រះមានព្រះភាគ ក្រាបថ្វាយបង្គំលាហើយ ជាបុគ្គលម្នាក់ឯង ចេញទៅប្រឹងប្រែងបដិបត្តិធម៌ មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្តផល ជាព្រះអរហន្ត ១ អង្គ

ក្នុងលោក[១] ។

## សង្ខេត និង បដិបត្តិ

១-ព្រះពុទ្ធ សម្តែងសង្កត់ធ្ងន់ថា អ្នកបដិបត្តិធម៌ (សមថៈ វិបស្សនា) ត្រូវសំអាតធម៌ខាងដើម គឺ សីល និង ទិដ្ឋិ មុន ។ **សីលំ សុវិសុទ្ធំ** សីលត្រូវស្អាតល្អ **ទិដ្ឋិ ឧជុកា** ទិដ្ឋិត្រូវតែត្រង់ ។ សីលស្អាត មិនចាំបាច់ដល់ថ្នាក់បរិសុទ្ធទេ ប៉ុន្តែ ត្រូវតែយកចិត្តទុកដាក់ មើលថែរក្សាសីលរបស់ខ្លួន បើឃើញថាល្អគួរសមហើយ ត្រូវតែចូលបដិបត្តិ សមាធិ បញ្ញា បន្តទៅទៀត កុំដេកចាំឲ្យសីលស្អាតបរិសុទ្ធសិន ហើយទើបចូលធ្វើសមាធិ... មុខជាមិនមានឱកាសហើយ ។ សូមជ្រាបថា សីល ជួយសមាធិ សមាធិ ជួយសីល ដូចដៃឆ្វេងដុសដៃស្តាំ ដៃស្តាំដុសដៃឆ្វេង លាងទឹកទៅ ស្អាតទាំងពីរ ។ ទិដ្ឋិត្រង់ មិនមែន សម្មាទិដ្ឋិ ជាន់ខ្ពស់ គ្រាន់តែជឿកម្ម ផល ចេះវិធីបដិបត្តិ ដឹងគោលបំណងនៃការបដិបត្តិ និង ផល នៃការបដិបត្តិ បានត្រឹមត្រូវ មិនមែនធ្វេចភ្លែកបដិបត្តិ តែប៉ុណ្ណោះ ទុកជាបានការហើយ ។

២-អាស្រ័យសីល តាំងនៅក្នុងសីល ហើយគប្បីចំរើននូវ សតិប្បដ្ឋាន ៤ ដោយចំណែក ៣ ។ កុំភ្លេចដោយចំណែក ៣ បើមិនចំរើនដោយចំណែក ៣ ឈ្មោះថា មិនទាន់គ្រប់លក្ខណៈ សតិប្បដ្ឋាន ៤ របស់ព្រះពុទ្ធ ទេ ។

---

[១]- សុត្តន្តបិដក ទីឃនិកាយ មហាវារវគ្គ ៣៨-៨-៥

# វិសុទ្ធិ ៧

សេចក្ដីស្អាត សេចក្ដីបរិសុទ្ធ នៃ ការបដិបត្តិធម៌ ហៅថា វិសុទ្ធិ ។ វិសុទ្ធិ មាន ៧ គឺ :

១-**សីលវិសុទ្ធិ** សេចក្ដីស្អាតនៃសីល ។ គឺរក្សាសីលឲ្យបរិសុទ្ធ តាមលំដាប់ថ្នាក់របស់ខ្លួន ឧបាសក ឧបាសិកា រក្សាសីល ៥ សីល ៨ សាមណេរ ភិក្ខុ រក្សាសីល ១០ សីល ២២៧ រក្សាសីល ប្រព្រឹត្តទៅដើម្បីសមាធិ ។ គម្ពីរវិសុទ្ធិមគ្គ ពោលថា បានដល់ចតុប្បារិសុទ្ធិសីល ។

២-**ចិត្តវិសុទ្ធិ** សេចក្ដីស្អាតនៃចិត្ត ។ គឺ អប់រំចិត្តឲ្យបរិសុទ្ធ ថ្នាក់សមាធិ ល្មមជាគ្រឹះនៃវិបស្សនាបាន ។ គម្ពីរវិសុទ្ធិមគ្គ ពោលថា បានដល់សមាបត្តិ ៨ (រូបឈាន និង អរូបឈាន) ព្រមទាំង ឧបចារ ។

៣-**ទិដ្ឋិវិសុទ្ធិ** សេចក្ដីស្អាតនៃទិដ្ឋិ ។ គឺ អប់រំចិត្តឲ្យបរិសុទ្ធ ថ្នាក់បញ្ញាដឹងនូវនាមរូប តាមសភាវៈពិត អាចគ្របសង្កត់នូវសេចក្ដីសំគាល់ថាសត្វ ថាបុគ្គល បាន ។ ព្រោះ មនុស្ស ឬ សត្វ ជាដើម បើគេរែកញែកដោយបញ្ញាដ៏ប្រពៃ មិនឃើញមានអ្វីក្រៅអំពី រូប និង នាម ទេ ។

៤-**កង្ខាវិតរណវិសុទ្ធិ** សេចក្ដីស្អាតនៃបញ្ញា ជាហេតុឆ្លងផុត នូវសេចក្ដីសង្ស័យបាន ព្រោះកំណត់ដឹងនូវបច្ច័យនៃនាមរូប ។ នាមរូបក្នុងអតីតកាលក្ដី នាមរូបក្នុងបច្ចុប្បន្នកាលក្ដី នាមរូបក្នុងអនាគតកាលក្ដី សុទ្ធតែកើតឡើងដោយហេតុបច្ច័យ មិនមានបុគ្គលណាអ្នកសាងទេ ។

៥-**មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** សេចក្ដីស្អាតនៃបញ្ញាដែលដឹងថាជាផ្លូវ ឬ មិនមែនផ្លូវទៅកាន់ព្រះនិព្វាន ។ អ្នកចំរើនវិបស្សនា កាលវិបស្សនូបក្កិលេស មានពន្លឺ ឬ បីតិ ជាដើម កើតឡើង អាចធ្វើឲ្យយល់ខុសថាខ្លួនបាន

សម្រេចមគ្គផល ។ នេះ ធ្វើឲ្យខូច ឬ រាំងស្ទះការបដិបត្តិធម៌ ។ បញ្ញាដែលមិនវង្វេង ដឹងថាជាផ្លូវ ឬ មិនមែនផ្លូវទៅកាន់ព្រះនិព្វាន ហៅថា មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ។

៦-**បដិបទាញាណទស្សនវិសុទ្ធិ** សេចក្តីស្អាតនៃបញ្ញា ដែលដឹងឃើញបដិបទា គឺផ្លូវបដិបត្តិក្នុងវិបស្សនា ចាប់ពីឧទយព្វយញ្ញាណ ដែលមិនមានឧបក្កិលេស រហូតដល់ អនុលោមញ្ញាណ ។ គេបដិបត្តិសាចុះសាឡើង ក្នុងវិបស្សនាញាណ ទាំង ៩ នេះ ។ បញ្ញាដែលស្អាតក្នុងរយៈនេះ ហៅថា បដិបទាញាណទស្សនវិសុទ្ធិ ។

៧-**ញាណទស្សនវិសុទ្ធិ** សេចក្តីស្អាតនៃញាណទស្សនៈ ឬ មគ្គញ្ញាណ គឺបញ្ញាដឹងច្បាស់ក្នុងអរិយមគ្គ ដែលកើតបន្ទាប់ពីគោត្រភូញាណឡើងទៅ ។ កាលមគ្គចិត្ត កើតឡើងហើយ ផលចិត្ត ក៏កើតឡើងភ្លាមក្នុងលំដាប់គ្នានោះ ។ ភាពជាអរិយបុគ្គល កើតឡើងដោយ ញាណទស្សនវិសុទ្ធិ នេះ[៧] ។

## សង្ខេប និង បដិបត្តិ

១-វិសុទ្ធិ ទី ១ គឺ សីល ។ វិសុទ្ធិ ទី ២ គឺ សមាធិ ឬ សមថៈ ។ វិសុទ្ធិ ទី ៣ ទី ៤ ទី ៥ ទី ៦ ទី ៧ គឺ បញ្ញា ឬ វិបស្សនា ។

២-វិសុទ្ធិ ទាំង ៧ នេះ គឺ ជាយានសំរាប់នាំទៅដល់ការសម្រេច មគ្គផល និព្វាន ។ យានទាំង ៧ នេះ ត្រូវតែអាស្រ័យគ្នា ចោលគ្នាមិនបានឡើយ ហើយក៏ត្រូវចាប់ផ្តើមពីយានទី ១ គឺ សីលវិសុទ្ធិ ទៅ ។

៣-ចិត្តវិសុទ្ធិ ពិតមែនតែ មិនអាចលះកិលេសដាច់ខាត មិនអាច

---

[៧]-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក ២១ / ៣០ / ៨០

ទៅដល់ព្រះនិព្វាន ក៏ពិតមែន ប៉ុន្តែ វាជួយអប់រំមនុស្សឲ្យល្អ ឲ្យបានសេចក្តីសុខ និង ជាឧបការដល់បញ្ញាផងដែរ ។ ដូចនេះ អ្នកមិនចូលចិត្ត សមាធិ (សមថៈ) មិនបដិបត្តិក៏បាន ប៉ុន្តែ កុំលុបលាង កុំប្រមាថ ព្រោះរឿងនេះ អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធ ជាដើម បានសម្តែងទុក ។

៤-បញ្ញា ឬ វិបស្សនា ។ វិធីបដិបត្តិរបស់ព្រះពុទ្ធ មានហើយ ប៉ុន្តែ បើមានវិធីអប់រំយ៉ាងម៉េចកើតបញ្ញាស្រួលជាង បដិបត្តិទៅ ប៉ុន្តែ កុំយល់ថា មានតែវិធីរបស់ខ្លួនទេ. ទើបកើតបញ្ញា មិនដូចនោះទេ វិធីរបស់គេ ក៏កើតបញ្ញាបានដែរ

៥-ព្រះនិព្វាន ជាបរមសុខ ។ នរណា សមគួរនឹងទៅមុន អញ្ជើញទៅមុន បណ្តើរ ៗ ទៅ កុំបង្ខំគេពេក... ។ មានគេមកជួបខ្ញុំ មានគេសរសេរសំបុត្រមកខ្ញុំថា អ្នកខ្លះ បង្ខំគេពេក... គឺប្រាប់ឲ្យគេឈប់គិតគូរអ្វី ។ ទាំងអស់ សូម្បីតែសេចក្តីទុក្ខលំបាកក្នុងជីវិតប្រចាំថ្ងៃ ក៏កុំគិត ព្រោះជារឿងតិចតួចទេ... យើងត្រូវតែប្តូរ ត្រូវតែស្រូតឲ្យអស់ពីសមត្ថភាព ដើម្បីបានសម្រេចព្រះនិព្វាន ឆាប់ ក្នុងពេលដ៏ប្រសើរនេះ ។ គេថា ដូចជា មិនសមគួរដល់កាលៈ ទេសៈ សព្វថ្ងៃនេះសោះ ។ ស្រុកទេស ទើបនឹងងើបពីនរក របស់បន ប៉ុល ពត ស្រាប់តែបបួលគ្នាឈប់គិតគូរ ម៉ែឪរត់ចោលកូនទៅរកព្រះ-និព្វាន ទុកឲ្យកូនអត់ឃ្លាន វេទនា ឯកា អនាថា... ។ សមបើពេលនេះប្រទេសជិតខាង កំពុងបញ្ចេញចង្កូមយ៉ាងនេះ... បញ្ហារឹតតែច្រើនរាប់មិនអស់ ។ តើ អនាគត កូនចៅរស់នៅ ដូចម្តេចទៅ... ម៉ែ ឪ ទៅរកនិព្វានអស់ មិនដឹងជាដល់ ឬ មិនដល់... កូនចៅ អាចទៅជាខ្ញុំកញ្ជះគេ ពេលហ្នឹង។

យើងធ្វើអ្នកបួស អ្នកសាសនា ត្រូវតែមានបញ្ញា ត្រូវតែគិតឲ្យគ្រប់ជ្រុងជ្រោយ កុំឲ្យធ្លោយ ត្រូវមួយ ខុសដប់ ងាប់គេឯងអស់ ដោយសារយើង ។

ប្រយ័ត្ន ! បាបដោយអចេតនា បាបដោយ អវិជ្ជា

# អនុបស្សនា ៧

១-**អនិច្ចានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនទៀង ។

២-**ទុក្ខានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាជាទុក្ខ ។

៣-**អនត្តានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ថាមិនមែនខ្លួន ។

៤-**និព្វិទានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ គួរឲ្យនឿយណាយ ។

៥-**វិរាគានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ គួរឲ្យប្រាសចាកតម្រេក ។

៦-**និរោធានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ គួរឲ្យរលត់កិលេស ។

៧-**បដិនិស្សគ្គានុបស្សនា** ការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ គួរឲ្យរលាស់ចោលនូវកិលេស ។

កាលពិចារណាឃើញរឿយ ៗ ថាមិនទៀង រមែងលះបង់សេចក្តីសំគាល់ថាទៀង "និច្ចសញ្ញា" ។ កាលពិចារណាឃើញរឿយ ៗ ថា ជាទុក្ខ រមែងលះបង់សេចក្តីសំគាល់ថាជាសុខ "សុខសញ្ញា" ។ កាលពិចារណាឃើញរឿយ ៗ ថា មិនមែនខ្លួន រមែងលះបង់សេចក្តីសំគាល់ថាជាខ្លួន "អត្តសញ្ញា" កាលនឿយណាយ រមែងលះបង់សេចក្តីរីករាយ "នន្ទិ" ។ កាលប្រាសចាកតម្រេក រមែងលះបង់សេចក្តីត្រេកត្រអាល "រាគៈ" ។ កាលរលត់ រមែង

លះបង់ការកើត "សមុទយៈ" ។ កាលរលាស់ រមែងលះបង់ការប្រកាន់ "អាទានៈ"[៨] ។

## សង្ខេត និង បដិបត្តិ

១-អនុបស្សនា ចេញមកពីកិរិយាសព្ទថា អនុបស្សតិ, អនិច្ចានុបស្សនា... ចេញមកពីបទថា អនិច្ចតោ អនុបស្សតិ... ។

២-អ្នកចំរើនវិបស្សនា គប្បីអប់រំឲ្យកើត អនុបស្សនា ទាំង ៧ គឺការពិចារណាឃើញរឿយ ៗ នូវបញ្ចក្ខន្ធ ឬ (កាយ វេទនា ចិត្ត ធម៌) ថាមិនទៀង ជាទុក្ខ ជាអនត្តា... ។ លុះតែកើត អនុបស្សនា ការពិចារណាឃើញរឿយ ៗ ឲ្យច្រើនឡើង ៗ ទើបកើត វិបស្សនា ការឃើញច្បាស់ តាមសេចក្ដីពិត។ ហេតុនេះ ត្រូវយកចិត្តទុកដាក់ខំបដិបត្តិ ។៚

## វិបស្សនាញាណ ៩

អ្នកចំរើនវិបស្សនា ពិចារណា សង្ខារធម៌ បញ្ចក្ខន្ធ រូប នាម ដោយត្រៃលក្ខណ៍ច្រើនឡើង ៗកើតវិបស្សនាញាណ ញាណក្នុងវិបស្សនា ដូចតទៅៈ

**១-ឧទយព្វយញាណ** ញាណគឺបញ្ញា ឃើញនូវការកើត និង ការរលត់ នៃសង្ខារធម៌ (នាមរូប) ។ នាមរូប កើតរលត់ ៗ ឥតឈប់ឈរ ។ ការឃើញទាន់ នូវការកើត និង ការរលត់ នៃ នាម រូប ក្នុងបច្ចុប្បន្ន ញ៉ាំងអនុសយក្កិលេសឲ្យរង្គើរង្គោះខ្លះ ៗ ហៅថា ឧទយព្វយញាណ ។

**២-ភង្គញាណ** ញាណ គឺ បញ្ញា ឃើញនូវការរលត់នៃសង្ខារធម៌

---

[៨]-សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ ៧១ / ១៩៨ / ៣២១

(នាម រូប) ។ ដោយបានបច្ច័យពី ឧទយព្វយញាណ មក ការពិចារណា ការកើតថយចុះ ការពិចារណាការរលត់ចំរើនឡើង ។ ធ្វើឲ្យឃើញកាន់តែច្បាស់ឡើងថា នាម រូប ទាំងអស់ ត្រូវតែរលត់ ដោយឥតមានមធ្យោបាយណាទប់ទល់បានឡើយ ។

៣-**ភយតូបដ្ឋានញ្ញាណ** ញាណ គឺ បញ្ញា ឃើញសង្ខារធម៌ (នាម រូប) គួរឲ្យភ័យខ្លាច ។ នាម រូប ឯណានីមួយ គ្រប់ភព គ្រប់ជាតិ ក្នុងកាល ណា ។ ក៏ដោយ នាម រូបគ្រប់ប្រភេទទាំងអស់នោះ ដូចជារណ្ដៅពេញដោយរងើកភ្លើង គួរឲ្យភ័យខ្លាច ព្រោះវានៅក្រោមច្បាប់ព្រះត្រៃលក្ខណ៍ អនិច្ចំ ទុក្ខំ អនត្តា ។

៤-**អាទីនវញ្ញាណ** ញាណ គឺ បញ្ញា ឃើញនូវទោសនៃសង្ខារធម៌ (នាម រូប) ។ គឺឃើញ នាម រូប ពេញដោយទុក្ខទោសច្រើនឡើង ។ មិនត្រូវការ ដូចបុរសឃើញអាហារ ពេញដោយថ្នាំពិស មិនហ៊ានបរិភោគ ដូច្នោះ ។

៥-**និព្វិទាញ្ញាណ** ញាណ គឺ បញ្ញា ឃើញនូវសង្ខារធម៌ (នាម រូប) គួរឲ្យនឿយណាយ ។ គឺឃើញ នាម រូប ពេញពោរដោយទុក្ខទោសនានប្បការ មិនប្រាថ្នា មិនរីករាយ មានតែនឿយណាយ ដូចសត្វលលកដែលនឿយណាយ ស្នូម្បីនៅក្នុងទ្រុងមាស ។

៦-**មុញ្ចិតុកម្យតាញ្ញាណ** ញាណ គឺ បញ្ញា ប្រាថ្នាចង់ឲ្យរួចផុតពីសង្ខារធម៌ (នាម រូប) ។ គឺឃើញ នាម រូប មានទុក្ខ មានភ័យ ច្រើនណាស់ មិនចង់នៅបនិត្យជិតជាមួយ នាម រូប ទៀតទេ ចង់ចេញឲ្យផុតពីនាម រូប ដូចសត្វកង្កែប ចង់ចេញឲ្យផុតពីមាត់ពស់ដូច្នោះ ។

៧-**បដិសង្ខាញ្ញាណ** ញាណ គឺ បញ្ញា វិលត្រឡប់មកពិចារណាសង្ខារធម៌ (នាម រូប) គ្រប់ជ្រុងជ្រោយ ឃើញថា ពេញពោរដោយទុក្ខច្រើន

នានប្បការ ហើយគិតរកឧបាយដើម្បីចេញឲ្យផុតពី នាម រូប នោះ ប្រៀប ដូចបុរសរុតត្រី យកអង្រុតគ្របជាប់ នឹកស្មានថាត្រី លូកដៃចូលទៅចាប់ ស្រាប់តែលើកចេញមកឃើញពស់វែក មានសេចក្ដីភ័យខ្លាច ហើយគិតរក ឧបាយលែងទៅវិញយ៉ាងណា កុំឲ្យពស់វាចឹកបាន ។ ញាណដែលកំពុងពិចារ ណារកឧបាយដូចនេះ ហៅថា បដិសង្ខាញាណ ។

៨-**សង្ខារុបេក្ខាញាណ** ញាណ គឺ បញ្ញា ពិចារណាឃើញ សង្ខារធម៌ នាមរូប មានទុក្ខមានទោសច្រើន ប៉ុន្តែ មិនភ័យ មិនត្រេកអរ មិនជាប់ជំពាក់ មានចិត្តព្រងើយ ប្រកបដោយ សតិសម្បជញ្ញៈ បដិបត្តិធម៌បន្តទៅទៀត ប្រៀបដូចបុរស ឃើញទោសរបស់ប្រពន្ធ បានលះលែងគ្នាដាច់ស្រឡះហើយ ទោះបីឃើញគេនិយាយជាមួយបុរសដទៃ ក៏មានចិត្តព្រងើយ មិនខឹង មិន ប្រច័ណ្ឌ ធ្វើការរបស់ខ្លួនតាមធម្មតាទៅ ។

៩-**អនុលោមញាណ** ញាណ គឺ បញ្ញា ប្រព្រឹត្តទៅអនុលោមតាម វិបស្សនាញាណ ទាំង ៨ ខាងដើមផង អនុលោមតាមពោធិបក្ខិយធម៌ ទាំង ៣៧ ប្រការផង ជាបញ្ញាមានសមត្ថភាពគ្រប់គ្រាន់ នឹងដឹងនូវកិច្ច ២ ក្នុងអរិយសច្ច ជាលោកិយ និង អនុលោមដល់ គោត្រភូញាណ ដើម្បីធ្វើកិច្ច ២ ក្នុងអរិយសច្ច ជាលោកុត្តរតទៅទៀត ។ ប្រៀបដូចព្រះរាជា ទ្រង់នូវគុណធម៌ គង់ប្រថាប់ ក្នុងសាលាវិនិច្ឆ័យ ទ្រង់ព្រះសណ្ដាប់ការវិនិច្ឆ័យ របស់មហាអាមាត្យទាំង ៨ នាក់ ព្រះអង្គមិនមានលំអៀង ទ្រង់តាំងព្រះទ័យជាកណ្ដាល ទ្រង់អនុលោមថា ចូរ កាត់សេចក្ដីយ៉ាងនេះឯង ទ្រង់អនុលោមចំពោះការវិនិច្ឆ័យរបស់មហាអាមាត្យ នោះ ព្រោះកាត់សេចក្ដីត្រូវតាមទំនងគន្លងធម៌ល្អហើយ និង ទ្រង់អនុលោម ចំពោះរាជធម៌ពីបូរាណរបស់ព្រះអង្គ គឺ ទសពិធរាជធម៌ ១០ ប្រការ មិនក្រោធ

មិនបៀតបៀន មានខន្តិ យ៉ាងណា អនុលោមញាណ ក៏យ៉ាងនោះ[៩] ។

## សង្ខេប និង បដិបត្តិ

១-ញាណក្នុង វិបស្សនា មិនមែន សុតាមយបញ្ញា បញ្ញាកើតពីការស្តាប់ ការរៀនសូត្រ ការអានសៀវភៅ និង មិនមែន ចិន្តាមយបញ្ញា បញ្ញាកើតពីការគិតទេ វាជា ភាវនាមយបញ្ញា គឺបញ្ញាកើតពីការអប់រំបដិបត្តិ (ធ្វើ) សមថៈ និង វិបស្សនា ។ ចង់ឃើញនគរវត្ត តែមិនព្រមទៅខេត្តសៀមរាប ចង់បាន វិបស្សនាបញ្ញា តែមិនព្រមធ្វើ សមថៈ វិបស្សនា មិនដឹងជាជួយយ៉ាងម៉េចកើត ។ ផ្លូវមានតែមួយទេ គឺធ្វើ សមថៈ វិបស្សនា នេះឯង ។ ព្រោះធម៌ទាំង ២ នេះ ជាធម៌គួរចំរើន ជាធម៌នាំឲ្យកើតវិជ្ជា គឺ បញ្ញា ។

២-គម្ពីរវិសុទ្ធិមគ្គ (ជាន់មុន) សម្តែងថា វិបស្សនាញាណមាន ៩ គម្ពីរអភិធម្មត្ថសង្គហៈ (ជាន់ក្រោយ) សម្តែងថា វិបស្សនាញាណមាន ១០ គឺថែមសម្មសនញាណ ១ មកទៀត ។ អាចារ្យជាន់ក្រោយ បន្ថែមញាណ ២ និង រួមបញ្ចូលញាណ ៤ ទៀត កើតទៅជា សោឡសញាណ ១៦ ។

## សោឡសញាណ ១៦

១-**នាមរូបបរិច្ឆេទញាណ** ញាណ គឺ បញ្ញា ដឹងថា នេះ នាម នេះ រូប ។ សង្ខារធម៌ទាំងឡាយ មានតែនាម និង រូប ប៉ុណ្ណោះ ។ ក្នុងលោកទាំងមូល គ្មានអ្វីក្រៅពី នាម និង រូប ឡើយ ។

២-**បច្ចយបរិគ្គហញាណ** ញាណ គឺ បញ្ញា ដឹងនូវបច្ច័យនៃ នាមរូប។ នាមធម៌ក្តី រូបធម៌ក្តី សុទ្ធតែអាស្រ័យហេតុបច្ច័យ ទើបកើតឡើងបាន បើមិន

---

[៩]- វិសុទ្ធិមគ្គ បដិបទាញាណទស្សនវិសុទ្ធិ

មានហេតុបច្ច័យ គឺកើតឡើងមិនបានទេ ។ នាមធម៌ក្តី រូបធម៌ក្តី ត្រូវតែអាស្រ័យហេតុបច្ច័យ ទើបស្ថិតនៅបាន បើអស់ហេតុបច្ច័យ វាត្រូវតែរលត់។

៣-**សម្មសនញ្ញាណ** ញាណ គឺ បញ្ញា ដឹងថា នាមរូប ត្រូវតែមានលក្ខណៈជា អនិច្ចំ ទុក្ខំ អនត្តា ។

៤-រហូតដល់ ១២ គឺ វិបស្សនាញាណ ៩ ។

១៣-**គោត្រភូញាណ** ញាណ គឺ បញ្ញា ដឹងច្បាស់នូវ នាម រូប ហើយទំលាយ (គ្របសង្កត់) គោត្របុថុជ្ជន ចូលទៅកាន់ គោត្រអរិយៈ ។

១៤-**មគ្គញាណ** ញាណ គឺ បញ្ញា ដឹងច្បាស់នូវ អរិយសច្ច ក្នុងអរិយមគ្គ ទាំង ៤ ។

១៥-**ផលញាណ** ញាណ គឺ បញ្ញា ដឹងច្បាស់នូវ អរិយសច្ច ក្នុងអរិយផល ទាំង ៤ ។

១៦-**បច្ចវេក្ខណញាណ** ញាណ គឺ បញ្ញា ដឹងច្បាស់នូវការត្រួតពិនិត្យនូវ មគ្គ ផល កិលេសដែលលះហើយ កិលេសដែលមិនទាន់បានលះ និង ព្រះនិព្វាន ។

ញាណ ទី ១ – ២ – ៣ – មិនមានក្នុងបាលី លោកមិនចាត់ជា វិបស្សនាញាណ ទេ ។ ញាណ ទី ៤ រហូតដល់ ញាណ ទី ១២ ទាំង ៩ នេះ ជា វិបស្សនាញាណ ។ អ្នកបដិបត្តិ វិបស្សនា ត្រូវខំអប់រំបណ្តុះបញ្ញាឲ្យកើតឡើងតាមលំដាប់នេះ ។ ញាណ ទី ១៣-១៤-១៥-១៦- យើងបុថុជ្ជនទៅមិនទាន់ដល់ទេ តែក៏ត្រូវសិក្សាឲ្យយល់ដែរ ដើម្បីជាគន្លងដែលយើងនឹងដើរទៅថ្ងៃមុខ ។

# មហាសារោបមសូត្រ

ខ្លឹមសារនៃព្រះសូត្រ

១-មហាសារោបមសូត្រ ប្រែថា សូត្រប្រៀបធៀបដោយខ្លឹមឈើដ៏ធំ[១០] ។

២-ដើមឈើមានអង្គប្រកប = មែកស្លឹក ក្រមរ សម្បក សាច់ស្រាយ សាច់ខ្លឹម ។ អ្នកត្រូវការខ្លឹមឈើ ត្រូវស្គាល់ខ្លឹមឈើ ត្រូវយកខ្លឹមឈើឲ្យបាន បើគេមិនស្គាល់ ច្រឡំយកមែកស្លឹកឈើ ឬ គេស្គាល់ខ្លឹម ប៉ុន្តែគេយកខ្លឹមឈើមិនបាន គេមិនបានអ្វីដែលជាប្រយោជន៍ពីខ្លឹមឈើនោះទេ ។

៣-អ្នកបួស ឬ អ្នកបដិបត្តិធម៌ ក្នុងសាសនា ត្រូវស្គាល់ព្រហ្មចរិយធម៌ដូចតទៅនេះ –

១-លាភសក្ការៈ និង សេចក្តីសរសើរ ជាមែកស្លឹកនៃព្រហ្មចរិយធម៌ ។

២-សីលសម្បទា ជាក្រមរនៃព្រហ្មចរិយធម៌ ។

៣-សមាធិសម្បទា ជាសម្បកនៃព្រហ្មចរិយធម៌ ។

៤-ញាណទស្សនៈ (ទិព្វចក្ខុ) ជាសាច់ស្រាយនៃព្រហ្មចរិយធម៌ ។

៥-អកុប្បា ចេតោវិមុត្តិ (អរហត្តផល) ជាសាច់ខ្លឹមនៃព្រហ្មចរិយធម៌។

ព្រះពុទ្ធ សម្តែងថា កុលបុត្រខ្លះ ចូលមកបួសរៀនក្នុងសាសនានេះ បានញុំាងលាភសក្ការៈ និង សេចក្តីសរសើរឲ្យកើតឡើង ហើយក៏ចាប់លើកខ្លួនបង្អាប់អ្នកដទៃ ជាអ្នកស្រើងវង្វេង ដោយលាភសក្ការៈ និង សេចក្តីសរសើរដែលជាមែកស្លឹកនៃព្រហ្មចរិយធម៌ ហើយក៏ដល់នូវសេចក្តីប្រមាទ មិនប្រឹងប្រែងធ្វើសេចក្តីល្អតទៅទៀត ។

---

[១០]- សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក ២១ / ៨៥ / ២១៦

កុលបុត្រខ្លះ បានសម្រេចសីលសម្បទា បរិបូរដោយសីល ហើយក៏ចាប់លើកខ្លួន បង្អាប់អ្នកដទៃ ជាអ្នកស្រើង វង្វេង ដោយសីលសម្បទា ដែលជាក្រមរនៃព្រហ្មចរិយធម៌ ហើយក៏ដល់នូវសេចក្ដីប្រមាទ មិនប្រឹងប្រែងធ្វើសេចក្ដីល្អ តទៅទៀត ។

កុលបុត្រខ្លះ បានសម្រេចសមាធិសម្បទា បរិបូរដោយ សមាធិ ហើយក៏ចាប់លើកខ្លួន បង្អាប់អ្នកដទៃ ជាអ្នកស្រើង វង្វេង ដោយសមាធិសម្បទា ដែលជាសម្បកនៃព្រហ្មចរិយធម៌ ហើយក៏ដល់នូវសេចក្ដីប្រមាទ មិនប្រឹងប្រែងធ្វើសេចក្ដីល្អតទៅទៀត ។

កុលបុត្រខ្លះ បានសម្រេចញាណទស្សនៈ (ទិព្វចក្ខុ) ហើយក៏ចាប់លើកខ្លួន បង្អាប់អ្នកដទៃ ជាអ្នកស្រើង វង្វេង ដោយញាណទស្សនៈ ដែលជាសាច់ស្រាយនៃព្រហ្មចរិយធម៌ ហើយក៏ដល់នូវសេចក្ដីប្រមាទ មិនប្រឹង-ប្រែងធ្វើសេចក្ដីល្អតទៅទៀត ។

កុលបុត្រខ្លះ មិនពេញចិត្ត មិនពេញតម្រិះក្នុងចិត្តត្រឹមតែ ដោយលាភសក្ការៈ និង សេចក្ដីសរសើរ ពេញចិត្តដោយសីលសម្បទា ដោយសមាធិសម្បទា ដោយញាណទស្សនៈ តែមិនពេញតម្រិះក្នុងចិត្តត្រឹមតែ ដោយសីលសម្បទា សមាធិសម្បទា ញាណទស្សនៈ (ព្រោះតម្រិះក្នុងចិត្តនៅមានទៀត គឺព្រះនិព្វាន) មិនលើកខ្លួន មិនបង្អាប់អ្នកដទៃ មិនស្រើង វង្វេង ដោយរឿងអស់នោះ ជាអ្នកដល់នូវសេចក្ដីមិនប្រមាទ ញុំាង អសមយវិមោក្ខ (អរហត្ត-ផល) ឲ្យកើតឡើង ។

ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះ មិនមែនមានលាភសក្ការៈ និងសេចក្ដីសរសើរ ជាអានិសង្ស មិនមែនមាន សីលសម្បទា ជាអានិសង្ស មិនមែនមាន សមាធិសម្បទា ជាអានិសង្ស មិនមែនមាន ញាណទស្សនៈ

ជាអានិសង្ស តែប៉ុណ្ណោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រហ្មចរិយធម៌នេះ មាន អកុប្បា ចេតោវិមុត្តិ ការរួចផុតចាកកិលេសនៃចិត្ត (គឺ អរហត្តផល) ដ៏មិនកម្រើក ជាប្រយោជន៍ ជាខ្លឹម ជាទីបំផុត ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះ មានចិត្តត្រេកអរ រីករាយចំពោះភាសិតនៃព្រះមានព្រះភាគ ៕ល៚

## សេចក្តីបន្ថែម

ព្រះសូត្រនេះ ព្រះពុទ្ធ សម្តែងចំពោះភិក្ខុ ប៉ុន្តែ មនុស្សទូទៅ ក៏ដូចគ្នា ។ អ្នកមានចំណេះវិជ្ជា អ្នកមានយសសក្តិ អ្នកមានទ្រព្យសម្បត្តិ មិនគប្បីលើកខ្លួន បង្អាប់អ្នកដទៃ ហើយស្រវឹង វង្វេង ដោយរឿងអស់នោះ ហើយដល់នូវសេចក្តីប្រមាទឡើយ ព្រោះសេចក្តីល្អនៅមានច្រើនតទៅទៀត ។ ព្រះលោកនាថ ប្រៀនប្រដៅមិនឲ្យប្រមាទ មិនឲ្យសន្តោស ក្នុងធម៌ទាំងឡាយជាកុសល ៕

## គតិ ៥

គតិ ដំណើរទៅរបស់សត្វ

១-និរយៈ នរក

២-តិរច្ឆានយោនិ សត្វតិរច្ឆាន

៣-បិត្តិវិសយៈ ប្រេត + អសុរកាយ

៤-មនុស្ស មនុស្ស

៥-ទេវ ទេវតា(១១) ។

---

(១១)-សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសក ២០-១៧០-២៧៨

សត្វដែលស្លាប់ រមែងទៅកាន់គតិទាំង ៥ នេះ ។ គតិ ៣ ខាងដើម ចាត់ជាទុគ្គតិ គតិ ២ ខាងចុង ចាត់ជាសុគតិ ។ អ្នកមានបាបច្រើន ទៅទុគ្គតិ អ្នកមានបុណ្យច្រើន ទៅ សុគតិ ។ ចាស់បូរាណ ពោលថា ទៅសុគតិ ដូចស្នែងគោ ទៅទុគ្គតិ ដូចរោមគោ ។

## ជីវិតរបស់មនុស្ស និង សត្វ

មនុស្សមានចំនួនតិច សត្វតិរច្ឆានមានចំនួនច្រើន ។ មនុស្សមានចំនួនតិចមែន តែមានបញ្ញាចេះច្នៃប្រឌិត គិតធ្វើអ្វីបានគ្រប់យ៉ាង សាងវប្បធម៌ អរិយធម៌ ចេះសាងបុណ្យកុសល សាងជីវិតការរស់នៅរបស់ខ្លួន ឲ្យខ្ពង់ខ្ពស់ ថ្លៃថ្នូរប្រសើរឡើង ។

ចំណែក សត្វតិរច្ឆាន មានចំនួនច្រើន មានកម្លាំងច្រើន សម្រាប់ឲ្យមនុស្សប្រើ តែមិនមានបញ្ញាចេះច្នៃប្រឌិតធ្វើអ្វីបានឡើយ... គ្មានទ្រព្យសម្បត្តិ គ្មានគ្រឿងសម្ភារៈ សំរាប់ជួយដោះស្រាយក្នុងពេលទុក្ខលំបាក ឬ ឈឺថ្កាត់ជាដើម ពេលឈឺ មិនដឹងបានចំណីអាហារមកពីណា ពេទ្យនៅឯណា... ជីវិតសត្វ គួរឲ្យអាសូរណាស់ ។ សត្វ មិនចង់បានសុខសប្បាយ មិនចង់មកកើតជាមនុស្សឬ ? ចង់ ! តែមកមិនបាន ព្រោះខ្វះបុណ្យ បុណ្យតិចពេក ។ សត្វណា មានបុណ្យគ្រប់គ្រាន់ ត្រូវតែបានមកកើតជាមនុស្ស ។

## កិច្ចោ មនុស្សប្បដិលាភោ

ការបានត្រឡប់មកកើតជាមនុស្ស ជាការកម្រ

ការទៅកើតជានេះជានោះ ក្នុងទីនេះទីនោះ មិនមែនទៅតាមសេចក្តីប្រាថ្នាទេ តែវាទៅតាមកម្លាំងកម្ម គឺ សេចក្តីល្អ អាក្រក់ ដែលគេធ្វើដោយ កាយ វាចា ចិត្ត ។ បើគេធ្វើសេចក្តីល្អច្រើន គេនឹងទៅកើតក្នុងស្ថានសួគ៌ ឬ ទៅកើត

ជាមនុស្ស ប៉ុន្តែ បើគេធ្វើសេចក្ដីអាក្រក់ច្រើន គេនឹងធ្លាក់ទៅក្នុងអបាយភូមិ នរក តិរច្ឆាន ប្រេត អសុរកាយ ។ បើគេធ្លាក់ទៅកើតក្នុងអបាយភូមិហើយ មិនងាយបានវិលត្រឡប់មកកើតជាមនុស្សវិញទេ ។ ព្រះពុទ្ធ ទ្រង់ប្រៀបធៀប ដូចអណ្ដើកខ្វាក់ក្នុងសមុទ្រ គេបោះកង ឬ រង្វង់មូលមួយ ទំហំធំជាងអណ្ដើក បន្តិច ទៅក្នុងមហាសមុទ្រ ដើម្បីឲ្យអណ្ដើកខ្វាក់ងើបដកដង្ហើមចូលក្នុងរង្វង់ មូលនោះ តើកាលណាទៅអណ្ដើកខ្វាក់នឹងងើបចូលក្នុងរង្វង់មូលបាន បើ សមុទ្រក៏ធំខ្យល់រលកក៏ច្រើន រង្វង់មូលក៏តូច... មិនងាយទេ កម្រណាស់ ។ ការបានត្រឡប់មកកើតជាមនុស្ស ក៏ដូច្នោះដែរ ។

អ្នកដែលបានមកកើតជាមនុស្ស ទោះបី ខ្មៅ ស ល្អ អាក្រក់ ចេះដឹង ល្ងង់ខ្លៅ មានទ្រព្យសម្បត្តិ ឬ ទីទ័លក្រយ៉ាងណាក្ដី ក៏ទុកជាលាភ ជាសំណាងល្អរបស់ខ្លួនហើយ ព្រោះមនុស្សយើង មានលទ្ធភាព មានតម្លៃ ជាងសត្វតិរច្ឆានច្រើនណាស់ ។ សូម្បីគេ ទ័លក្រ ពិកលពិការ ឬ ឈឺថ្កាត់ ក៏គេអាចធ្វើសេចក្ដីល្អ សាងបុណ្យកុសល បានដែរ ។ ចំណែក សត្វតិរច្ឆាន ធ្វើដូចនេះ មិនបានទេ ។

ព្រោះហេតុនោះ មនុស្សយើងគ្រប់គ្នា មិនគប្បីជាអ្នកមានសេចក្ដី ប្រមាទ យកភាពជាមនុស្សរបស់ខ្លួន ទៅប្រព្រឹត្តទុច្ចរិតផ្សេងៗ ល្បែងអបាយ មុខ ពាលាអាភ័ស ឬក៏ សប្បាយ ហេ ! ហា ! ខាតពេលវេលា អស់ ទ្រព្យសម្បត្តិ ឥតប្រយោជន៍ឡើយ ព្រោះភាពជាមនុស្ស បានមកដោយដើម ទុន គឺ បុណ្យកុសលច្រើនណាស់ ។ មិនសមគួរទេ មិនរួចតម្លៃដើមទេ ប្រយ័ត្ន ! តែធ្លាក់ខ្លួនហើយ ដោយឡែកក្នុងអបាយភូមិ មិនងាយបានត្រឡប់ មកវិញទេ ។

ជាការប្រសើរណាស់ មនុស្សយើង គប្បីជាអ្នកភ្ញាក់រលឹក ធ្វើសេចក្ដី

ល្អ កសាងខ្លួនឲ្យសមនឹងឋានៈជាមនុស្ស ដឹងខុស ត្រូវ អាក្រក់ ល្អ ប្រកបរបរចិញ្ចឹមខ្លួន ចិញ្ចឹមគ្រួសារ មាតាបិតា និង ញាតិមិត្រ ព្រមទាំង រួមចំណែកជួយកសាង ប្រទេសជាតិ សាសនា របស់ខ្លួនផង ។ **បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ** សេចក្តីល្អ បុណ្យកុសលទាំងឡាយ រមែងបានជាទីពឹង របស់សត្វទាំងឡាយ តាំងពីបច្ចុប្បន្ននេះ រៀងរហូតដល់ លោកខាងមុខទៀត ៕

## បុញ្ញកិរិយាវត្ថុ

### ទីតាំងនៃការធ្វើបុណ្យ ៣ យ៉ាង

១-**ទានមយៈ** បុណ្យកើតឡើងដោយការឲ្យទាន ។

២-**សីលមយៈ** បុណ្យកើតឡើងដោយការរក្សាសីល ។

៣-**ភាវនាមយៈ** បុណ្យកើតឡើងដោយការចំរើន (អប់រំ) (១២) ។

ទានៈ ការឲ្យ បើនិយាយពីអ្វីដែលគេឲ្យ មាន ២ យ៉ាង គឺ ១-**អាមិសទាន** ការឲ្យវត្ថុ ទ្រព្យធន ២-**ធម្មទាន** ការឲ្យគំនិត ចំណេះវិជ្ជាធម៌ ។ ធម្មទាន ប្រសើរជាង អាមិសទាន ។ បើនិយាយពីទឹកចិត្តដែលគេឲ្យ មាន ៣ គឺ ១-**សង្គហទាន** ការឲ្យដោយចិត្តសង្គ្រោះ មេត្តា ករុណា ២-**បូជាទាន** ការឲ្យដោយចិត្ត គិតឃើញគុណ បូជាគុណ ៣-**ចាគទាន** ការឲ្យដោយចិត្ត លះសេចក្តីកំណាញ់ សេចក្តីជាប់ជំពាក់ ។ ចាគទាន ប្រសើរជាងទាន ២ ខាងដើម ។

អ្នកធ្វើទាន មិនមែនគ្រាន់តែឲ្យគេទេ ឈ្មោះថាឲ្យខ្លួនឯងដែរ ។ ពាក្យ

---

(១២)-សុត្តន្តបិដក ខុទ្ទកនិកាយ ឥតិវុត្តកៈ ៥៣ / ៦០ / ៦៩

ចាស់ថា ចេកទៅ អំពៅមក ។ អស់លោកិយទ្រព្យ បានអរិយទ្រព្យ ។ អស់ទ្រព្យខ្លះមែន តែបានសេចក្តីសុខ...។ ការឲ្យទាន ឈ្មោះថាជញ្ជូនទ្រព្យចេញពីអន្តរាយ ឈ្មោះថាបានកប់ទុកក្នុងទីដ៏ប្រសើរ ឈ្មោះថាបានសន្សំស្បៀងទុកសំរាប់ធ្វើដំណើរក្នុងសំសារវដ្ត ។ អ្នកមិនធ្វើទាន គឺអ្នកធ្វើបាបខ្លួនឯង ៕

សីល បានដល់ការរក្សា កាយ វាចា ឲ្យប្រក្រតី ឲ្យរៀបរយ គឺមិនសម្លាប់សត្វ មិនលួចប្លន់... ទ្រព្យគេ មិនប្រព្រឹត្តខុសប្រពៃណី ប្តីប្រពន្ធ កូន ចៅ គេ មិននិយាយកុហក មិនផឹកសុរា មេរ័យ គ្រឿងញៀន នេះ គឺ សីល ៥ ។ ការប្រព្រឹត្តវត្ត ក្នុងថ្ងៃឧបោសថ មិនសេពមេថុន... មិនបរិភោគអាហារពេលរសៀលជាដើម នេះ ជាសីលព្រត គឺ សីលឧបោសថ ។ សីលេ ជាមេបុណ្យ ទ្រទ្រង់នូវបុណ្យកុសលឯទៀតៗ ឲ្យដុះដាលរីកចំរើនឡើង ។ សីល ជាគ្រឿងតុបតែងលំអដ៏ប្រសើរ ប្រើបានគ្រប់ជាតិ គ្រប់សាសន៍ គ្រប់ភេទ គ្រប់វ័យ ។ មនុស្សមានសីល គួរសេពគប់ គោរពរាប់អាន មនុស្សអត់សីលសាមាន្យ មិនគួរទុកចិត្តឡើយ ៕

ភាវនា បូរាណប្រែថា ការចំរើន សម័យប្រែថា ការអប់រំ មកពីកិរិយាសព្ទថា ភាវេតព្វា ធម៌ដែលគេគប្បីចំរើន ។ ពាក្យថាចំរើន គឺ ធ្វើអ្វីដែលមិនទាន់កើត មិនទាន់មាន ឲ្យកើតឲ្យមានឡើង ដែលកើតមានហើយ ឲ្យរឹតតែចំរើនច្រើនឡើងៗ ។ ភាវនា មាន ៤ យ៉ាង គឺ :

១-កាយភាវនា ការអប់រំឲ្យចេះ ដើរ ឈរ អង្គុយ ដេក ចេះទុកដាក់ខ្លួនឲ្យមានអាកប្បកិរិយា ឫកពា សុភាពរាបសា ចេះប្រើ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ឲ្យកើតប្រយោជន៍ច្រើន ចេះថែរក្សាខ្លួន និង ស្លៀកពាក់

ឲ្យសមរម្យ ចេះរៀបចំទុកដាក់ប្រើប្រាស់ឲ្យមានរបៀប សណ្ដាប់ធ្នាប់ល្អ ។

២-សីលភាវនា ការអប់រំឲ្យមានសីលធម៌ ចេះរក្សាសីល សង្រួមឲ្យសមតាមភូមិភេទរបស់ខ្លួន និយាយរួម គឺ ប្រកបព្រមដោយ សម្មាកម្មន្ត សម្មាវាចា សម្មាអាជីវៈ ។

៣-ចិត្តភាវនា ការអប់រំចិត្តឲ្យចេះស្រឡាញ់ប្រយោជន៍រួម ឲ្យមានយុត្តិធម៌ ឲ្យមាន មេត្តា ករុណា ឲ្យចេះអត់ធន់ តស៊ូប្រឹងប្រែង និង ស្ងប់រម្ងាប់ និយាយរួមគឺ ប្រកបព្រមដោយ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។

៤-បញ្ញាភាវនា ការអប់រំចិត្តឲ្យមានបញ្ញា ស្គាល់បាប បុណ្យ គុណ ទោស ខុស ត្រូវ ខាត ចំណេញ ប្រយោជន៍ មិនមែនប្រយោជន៍ និង ឃើញច្បាស់នូវសភាវធម៌តាមសេចក្ដីពិត និយាយរួមគឺ ប្រកបព្រមដោយ សម្មាទិដ្ឋិ សម្មាសង្កប្បៈ[១៣] ។

ភាវនា ៤ យ៉ាងនេះ បើគេបដិបត្តិតាមត្រឹមត្រូវម៉ត់ចត់ គេនឹងបាន សម្រេចមគ្គ ផល ដល់ទីបំផុត ។ ភាវនា ៤ យ៉ាងនេះ ៣ ខាងដើម ចាត់ជា សមថភាវនា ១ ខាងចុង ចាត់ជា វិបស្សនាភាវនា ។

## ភាវនា ២ យ៉ាង

១-**សមថភាវនា** ការអប់រំចិត្តឲ្យស្ងប់ ។

២-**វិបស្សនាភាវនា** ការអប់រំចិត្តឲ្យមានបញ្ញា ។

---

[១៣]-សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចកនិបាត ៤៤.៧៩.២២១
ប្រើជាគុណបទ របស់បុគ្គលជា អភាវិតកាយ ភាវិតកាយ...
ប្រើជាបធានបទ ជា កាយភាវនា... ។

សមថភាវនា ការអប់រំចិត្តឲ្យស្ងប់ ។

តាមធម្មតា ចិត្ត ជាធម្មជាត ញាប់ញ័រ ឃ្លេងឃ្លោង តែងទទួលអារម្មណ៍ផ្សេងៗ តាមទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត ឥតឈប់ឈរ មិនស្ងៀមនៅនឹង មិនស្ងៀមស្ងប់ទេ ។ ចិត្តដែលមិនស្ងប់ អណ្ដែតអណ្ដូង ជាចិត្តសៅហ្មងផង ជាចិត្តមានកម្លាំងខ្សោយផង មិនអាចធ្វើការអ្វីឲ្យមានប្រសិទ្ធិភាពបានទេ ។ ហេតុនេះ គេត្រូវតែរកវិធីអប់រំចិត្តឲ្យស្ងប់ ។ វិធីនេះ ហៅថា សមថភាវនា ។ អានាបានស្សតិ ជាវិធីអប់រំចិត្តឲ្យស្ងប់មួយនៃសមថភាវនា នោះ ។

## អានាបានស្សតិ

អានាបានស្សតិ តើគេត្រូវបដិបត្តិដូចម្ដេច

ព្រះពុទ្ធ ប្រាប់អានន្ទ ថា ១-ត្រូវរកទីកន្លែង ព្រៃ គល់ឈើ ផ្ទះស្ងាត់ ២-អង្គុយតាំងកាយឲ្យត្រង់ ផ្ចង់សតិឆ្ពោះទៅរកអារម្មណ៍ របស់ កម្មដ្ឋាន ។ ៣-ដកដង្ហើមចូល មានសតិ (ស្មារតី) ដកដង្ហើមចេញមានសតិ ។ មិនមានអ្វីពិបាកយល់ទេ ប្រការសំខាន់ ត្រូវមានសតិជានិច្ច គឺ កុំឲ្យបាត់សតិ ។

បន្ទាប់មក ព្រះពុទ្ធ ទ្រង់សម្ដែង វិធីដកដង្ហើម ១៦ ចំណុច ដើម្បីឲ្យទៅជា សតិប្បដ្ឋាន ៤ ។ ខ្ញុំ អាត្មា សូមលើកយកតែ ៤ ចំណុច ដើម្បីជាឧទាហរណ៍ -

១-កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។

២-កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី។

៣-ភិក្ខុសិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចូល សិក្សាថា អាត្មាអញ ដឹងច្បាស់នូវកាយទាំងពួង ដកដង្ហើមចេញ ។

៤-ភិក្ខុសិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចូល សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ ដកដង្ហើមចេញ ។

វិធីដកដង្ហើម ៤ ចំណុចនេះ ត្រូវបន្ថែមសញ្ញា កំណត់ចំណាំឲ្យដឹងថា វែង ខ្លី ត្រូវសិក្សាឲ្យដឹងច្បាស់នូវកាយ គឺខ្យល់ដកដង្ហើមទាំងពួង គឺគេមានសតិ ដឹងខ្យល់ដកដង្ហើម ចូល ចេញ រហូត អត់មានភ្លាត់សតិ និង ត្រូវសិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារ គឺ ខ្យល់ដកដង្ហើមចូល ចេញគ្រោតគ្រាត ដកដង្ហើមចូល ចេញ ។

សមថភាវនា ត្រូវការតែប៉ុណ្ណឹង អត់ត្រូវការពិចារណាអ្វីទាំងអស់ ។ បើគេធ្វើបានយ៉ាងនេះ ហើយសតិរបស់គេ អត់បណ្តោយឲ្យអារម្មណ៍អ្វីមួយចូលមកជ្រៀតជ្រែកក្នុងខណៈ ដកដង្ហើមនោះទេ គេឈ្មោះថា មានចិត្តស្ងប់ហើយ គេបានបុណ្យហើយ បុណ្យនេះ ប្រសើរជាង ការធ្វើទាន និង ការរក្សាសីល ទៀតផង ។ ប៉ុន្តែ គេ កាត់កិលេស មិនទាន់ដាច់ទេ គេត្រូវតែចំរើនវិបស្សនាភាវនា តទៅទៀត ។

វិបស្សនាភាវនា ការអប់រំចិត្តឲ្យមានបញ្ញា ។

បញ្ញា ក្នុងទីនេះ មិនសំដៅយកបញ្ញាផ្លូវលោក សំរាប់រៀនសូត្រ សំរាប់ធ្វើការ ប្រកបមុខរបរទេ ប៉ុន្តែ សំដៅយកបញ្ញាផ្លូវធម៌ សំរាប់ដឹង

ច្បាស់នូវ សង្ខារធម៌ ឬ សភាវធម៌ តាមសេចក្ដីពិត (របស់វា) ។

សង្ខារធម៌ គឺ អ្វីដែលរួមគ្នាកើតឡើង (មានហេតុ មានបច្ច័យ) ទោះបី មានវិញ្ញាណក្ដី មិនមានវិញ្ញាណក្ដី មានរូបក្ដី មិនមានរូបក្ដី ។ សភាវធម៌ គឺ អ្វី ដែលមានឡើងតាមសភាវៈរបស់វា ទោះបីជាសង្ខតធម៌ក្ដី អសង្ខតធម៌ក្ដី។

វិបស្សនាបញ្ញា ចង់ដឹងច្បាស់ នូវសង្ខារធម៌ ឬ សភាវធម៌ ហ្នឹង តាម សេចក្ដីពិត ។ តើវាកើត វាមានមកយ៉ាងម៉េច ? នរណាបង្កើតវា ? វា ទៀង ឬ មិនទៀង ? វា សុខ ឬ ទុក្ខ ? វា ជា អត្តា ឬ ជា អនត្តា ?... ជាអញ ? ជាឯង ?

សូមបញ្ជាក់ម្ដងទៀតថា វិបស្សនាបញ្ញា មិនមែនជា សុតាមយបញ្ញា មិនមែនជា ចិន្តាមយបញ្ញា ទេ វាជា ភាវនាមយបញ្ញា គឺ បញ្ញាកើតពីការ បដិបត្តិ ។ ដូចនេះ ការអប់រំចិត្តឲ្យមានបញ្ញា ត្រូវយកចិត្តដែលបដិបត្តិ បាន ស្ងប់ខ្លះហើយនោះ ទៅបណ្ដុះឲ្យកើតបញ្ញា បានសេចក្ដីថា យើងត្រូវធ្វើ សមថៈ ឲ្យបានស្ងប់បន្តិចសិន សឹមយកចិត្តដែលស្ងប់នោះទៅចំរើន វិបស្សនា ។

ឧទាហរណ៍ - យើងចំរើន អានាបានស្សតិ មានសតិ តាំងនៅមាំ ដឹងខ្យល់ ចូល ចេញ វែង ខ្លី... តែអត់មានពិចារណាអ្វីទេ ចិត្តស្ងប់ត្រឹមប៉ុណ្ណោះ នេះ ហៅថា សមថៈ (សមាធិ) ហើយ ។ យើងយកចិត្តដែលកំពុងស្ងប់នេះ ពិចារណាខ្យល់ដកដង្ហើម តើខ្យល់កើតឡើងយ៉ាងម៉េច វាទៀង ឬ មិនទៀង... វាជាអ្វី ជាសត្វ ជាបុគ្គល... យើងកើតបញ្ញាភ្លឺស្វាង ដឹងសេចក្ដីពិត ជម្រុះ កិលេសបានខ្លះ ៗ នេះ ជា វិបស្សនា ហើយ ។

ម្យ៉ាងទៀត ដោយអារម្មណ៍ខ្លះ របស់សមថៈ មិនអាចយកជា អារម្មណ៍ របស់ វិបស្សនា បាន ពេលដែលយើងកំពុងមានចិត្តស្ងប់នោះ យើងអាចប្ដូរយកអារម្មណ៍ថ្មី មានខន្ធ ៥ ជាដើម មកពិចារណាឲ្យឃើញហេតុ

បច្ច័យ កើត រលត់ អនិច្ចំ ទុក្ខំ អនត្តា បញ្ញាភ្លឺស្វាង ដឹងសេចក្តីពិត កិលេសថយចុះតាមកម្រិតនៃបញ្ញានោះៗ នេះ ជា វិបស្សនា ហើយ ។

## អានិសង្ស នៃ សមថៈ វិបស្សនា

គេតែងនិយាយថា អ្នកចំរើនសមថៈ វិបស្សនា លុះស្លាប់ទៅ គេនឹងបានកើតក្នុងស្ថានសួគ៌ បើមានឧបនិស្ស័យគ្រប់គ្រាន់ គេនឹងបានសម្រេចព្រះនិព្វាន ។ គេនិយាយនោះ មិនខុសទេ ប៉ុន្តែ ផលប្រយោជន៍ នៃ សមថៈ វិបស្សនា មិនមែនសំរាប់តែជាតិមុខប៉ុណ្ណោះទេ គឺដើម្បីសេចក្តីសុខ ចំរើន ក្នុងជាតិនេះផងដែរ ។

មនុស្សយើងមាន ២ ចំណែក គឺ កាយ និង ចិត្ត ភាសាធម៌ថា រូប និងនាម ។ កាយ អត់ដឹងអីទេ ចិត្តអ្នកដឹកនាំ ។ បើចិត្ត មិនស្ងប់ មិនភ្លឺស្វាង មិនសុខហើយ រមែងនាំកាយទៅរកទុក្ខលំបាក ។ ដូចនេះ មានតែ សមថៈ វិបស្សនា នេះ អាចជួយធ្វើចិត្តឲ្យស្ងប់ ឲ្យភ្លឺស្វាង ដឹងខុសត្រូវ ដឹកនាំដើរទៅរកផ្លូវសុខ ចំរើន ដល់ខ្លួន និង អ្នកដទៃបាន ។ ហេតុនេះ អ្នកទាំងឡាយ កុំគប្បីប្រមាទ ចូរចំរើន សមថៈ វិបស្សនា ឲ្យបានសម្រេចប្រយោជន៍ចុះ ៕

**សមថ វិបស្សនា ជាបុណ្យធំជាងបុណ្យអ្វីទាំងអស់**

**គ្មានបុណ្យអ្វីធំ ស្មើនឹងការចំរើន សមថ វិបស្សនា ទេ**

## នត្ថិ អត្តសមំ បេមំ

មិនមាន ស្រឡាញ់អ្វី ស្មើនឹងស្រឡាញ់ខ្លួន

បើស្រឡាញ់ខ្លួន កុំស្រឡាញ់តែរូបកាយ ត្រូវស្រឡាញ់ចិត្តផង
បើបំប៉នចំណីរូបកាយ ត្រូវបំប៉នចំណីចិត្តផង
បើថែរក្សារូបកាយ ត្រូវថែរក្សាចិត្តផង

ប៉ុន្តែ
កុំធ្វើអ្វី តាមតែចិត្តគិត តាមតែចិត្តចង់
ព្រោះចិត្តដែលមិនបានអប់រំ នាំទៅរកទុក្ខលំបាកច្រើនណាស់

## សមថ វិបស្សនា ជាវិធីអប់រំប្រសើរបំផុត

គ្មានវិធីអប់រំណា ស្មើនឹង សមថវិបស្សនា ទេ ៖

៙*៙

# សំណួរ ចម្លើយ

១-សំណួរ បុគ្គលខ្លះ និយាយថា ខ្ញុំ មិនចាំបាច់បដិបត្តិធម៌ អ្វីទៀតទេ ព្រោះខ្ញុំអត់មានធ្វើអ្វីខុសផង តើគំនិតនេះ យកជាការបានឬទេ ?

ចម្លើយ – បុគ្គលគ្រប់រូប មានសេរីភាព... កុំបង្ខំគេ ។ បើគេអស់កំហុសមែន ជាការប្រសើរណាស់ ប៉ុន្តែ គួរសួរបញ្ជាក់ថា ពាក្យថា អត់មានធ្វើអ្វីខុស តើសំដៅសេចក្តីត្រឹមណា ? លោកអស់កិលេសហើយឬនៅ ? បើគេសំដៅត្រឹមតែមិនសម្លាប់សត្វ មិនលួចទ្រព្យគេ... ប៉ុណ្ណឹងជាដើម មិនទាន់ចប់កិច្ចទេ នៅមានធម៌ដែលត្រូវបដិបត្តិ ទៀត ច្រើនណាស់ ។ សូម្បីតែអ្នកបានធ្វើចប់កិច្ចសម្រេចធម៌ បានជាព្រះអរហន្ត ហើយ ក៏គង់លោកនៅបដិបត្តិធម៌ ដើម្បីសេចក្តីសុខ សតិ សម្បជញ្ញៈ និង ទិដ្ឋានុគតិ ដែរ ។

២-សំណួរ – អ្នកខ្លះ និយាយថា ខ្ញុំធ្វើទាន រក្សាសីល ប៉ុណ្ណេះគ្រប់គ្រាន់ហើយ តើគំនិតនេះ ត្រឹមត្រូវឬទេ ?

ចម្លើយ – ត្រូវ ! តែមិនទាន់ត្រឹម ។ គេចេះធ្វើទាន រក្សាសីល ប៉ុណ្ណេះ ល្អរបស់គេហើយ គួររាប់អាន គួរគោរព ប៉ុន្តែ មិនទាន់គ្រប់គ្រាន់ទេ ។ ព្រោះធម៌ក្រុមនេះ មាន ៣ គឺ ទាន សីល ភាវនា ឬ សីល សមាធិ បញ្ញា ។ បើគេធ្វើបានតែ ទាន សីល នៅខ្វះ ភាវនា មួយទៀត បើគេធ្វើបានតែ សីល នៅខ្វះ សមាធិ និង បញ្ញា ទៀត តើថាគ្រប់គ្រាន់ម៉េចកើត ។ ហេតុអ្វី ក៏ចាំបាច់ឲ្យគ្រប់ទាំង ៣ ព្រោះកិលេសមាន ៣ ក្រុម កិលេសគ្រោតគ្រាត កំចាត់ដោយ ទាន សីល កិលេសកណ្តាល និង កិលេសល្អិត កំចាត់ដោយភាវនា ឬ និយាយមួយបែបទៀតថា វីតិក្កមកិលេស កំចាត់ដោយសីល បរិយុដ្ឋានកិលេស កំចាត់ដោយ សមាធិ អនុសយក្កិលេស កំចាត់ដោយបញ្ញា

ហេតុនេះ គេត្រូវតែខំបដិបត្តិឲ្យគ្រប់ទាំង ៣ ទើបអាចរំលត់ទុក្ខសព្វគ្រប់បាន។

៣-សំណួរ - ខ្ញុំ ទៅរៀនធ្វើ សមថៈ ជាមួយគេដែរ ប៉ុន្តែ មិនបាន ស្ងប់សោះ តើបានបុណ្យឬទេ ? ដើម្បីឲ្យបានស្ងប់ តើត្រូវធ្វើដូចម្ដេចទៅ ?

ចម្លើយ – ធ្វើមុនដំបូង វាមិនស្ងប់អីចឹងហើយ ធ្វើយូរ ៗ ទៅ គង់តែបានស្ងប់ទេ ។ កុំតូចចិត្ត គេភាគច្រើនក៏មិនស្ងប់ ដូចជាយើងដែរ ។ អត់ធន់ទៅ ព្យាយាមទៅ ! បើមិនស្ងប់អីចឹង បានបុណ្យដែរ ? បាន ! បានគ្រប់តែគ្នា ឲ្យតែទៅធ្វើ... ។ និទាន សត្វប្រចៀវ ៥០០ នៅក្នុងរូងភ្នំ ជាមួយព្រះសង្ឃធ្វើធុតង្គ ពេលលោកស្វាធ្យាយធម៌ សត្វប្រចៀវ សម្ងំ មិនយំ មិនស្រែក គ្រាន់តែប៉ុណ្ណឹង លុះស្លាប់ទៅ បានទៅកើតជាទេវតា ច្យុតពីនោះចុះមកកើតជាមនុស្ស បានបួសជាភិក្ខុ ៥០០ សិស្សរបស់ព្រះសារីបុត្រ រៀនសូត្រអភិធម្ម បានចេះចាំមុនគេ ។ មនុស្សយើង មិនមែនអន់ជាងប្រចៀវទេ យើងមានគុណធម៌ សទ្ធា ជ្រះថ្លា វីរិយ ព្យាយាម ជាដើម ច្រើនណាស់ គុណធម៌កើតហើយ ត្រូវតែបានបុណ្យ ។

រឿងមិនស្ងប់ វាមានហេតុរបស់វា យើងត្រូវតែរកហេតុ កែហេតុ។ ចិត្តមិនស្ងប់ព្រោះ – មានកិច្ចធុរៈ ជាប់ជំពាក់ច្រើន, ចំណីអាហារច្រើន, ទីកន្លែងអាប់អួ, ព្យាយាមខ្លាំងពេក ឬ អារម្មណ៍មិនសមនឹងចរិតរបស់ខ្លួនជាដើម។ យើងត្រូវសង្កេត ពិនិត្យ កែលំអ អប់រំបន្ទំនិស្ស័យ អត់ធន់ តស៊ូ យូរអង្វែងរឿយ ៗ ទៅ ។ បើព្យាយាមយ៉ាងនេះហើយ នៅតែមិនស្ងប់ មិនបានផល យើងគប្បីផ្លាស់ពីធ្វើសមថៈ មុន មកធ្វើ វិបស្សនា មុន ម្ដង គឺចាប់ចំរើន វិបស្សនា ពិចារណាខ្លួនយើង គឺ បញ្ចក្ខន្ធ ដោយឋានៈ ៧ និង វិធី ៣ ដែលព្រះជិនស្រី សម្ដែងទុក ក្នុងគម្ពីរ សំយុត្តនិកាយ ខន្ធវារវគ្គ ពិចារណា

រឿយ ៗ ចិត្តស្ងប់ ពិចារណាតទៅទៀត កើតបញ្ញា ច្រើនឡើង ៗ ជាលំដាប់ យើងឈ្មោះថា បានសម្រេចទាំងវិបស្សនា ទាំង សមថៈ ។

៤-សំណួរ – គេនិយាយថា មិនមែនខ្លួន មិនមានខ្លួន តើបាន សេចក្ដីថា យ៉ាងម៉េច ? ខ្ញុំស្ដាប់មិនបាន ខ្ញុំមិនយល់... ខ្លួននៅមានជ្រងោ គ្រប់តែគ្នា ហើយនិយាយថា មិនមែនខ្លួន មិនមានខ្លួន តើបានប្រយោជន៍ អ្វី ?

ចម្លើយ – ខ្លួនយើង ដែលជាធាតុ ដី ទឹក ភ្លើង ខ្យល់ ឬថា សក់ រោម ក្រចក ធ្មេញ ស្បែក វាមានពិតប្រាកដមែន មិនមែនជាគ្មានទេ នរណាក៏ដឹងដែរ ។ ប៉ុន្តែ ពាក្យថា មិនមែនខ្លួន មិនមានខ្លួននេះ ជាឱវាទ របស់ព្រះពុទ្ធ ។ ព្រះអង្គ ទ្រង់ពន្យល់ថា អ្វីដែលជារបស់យើង គឺយើងមាន អំណាចលើវា យើងអាចបង្គាប់បញ្ជាវាបាន ឲ្យវាទៅជាយ៉ាងនេះ យ៉ាងនោះ ។ ចំណែក រូបកាយយើង យើងបង្គាប់កុំឲ្យចាស់ កុំឲ្យឈឺ កុំឲ្យស្លាប់ បង្គាប់ វាមិនបាន វាប្រព្រឹត្តទៅតាមរឿងរបស់វាជាដរាប ដូចនេះ មិនឈ្មោះថា ខ្លួនយើង ឬ របស់យើងទេ គឺ មិនមែនខ្លួនយើងទេ ។ ម្យ៉ាងទៀត បុគ្គលខ្លះ ជឿថា ក្នុងខ្លួនយើងមានអ្វីពិសេស (អត្តា ឬ ព្រលឹង) អាស្រ័យនៅ អ្វីនោះ ហើយ គឺជា ខ្លួនយើង ។ ព្រះពុទ្ធ សម្ដែងថា ខ្លួនយើង គឺ ខន្ធ ៥ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ។ មិនមានអ្វីលើសពីនេះ មិនមាន អ្វីដែលគេយល់ថាជាខ្លួន អាស្រ័យនៅទេ មានតែខន្ធ ៥ ប៉ុណ្ណោះ ។ ខន្ធ ៥ មិនមែនខ្លួនយើងទេ វាមិនស្ដាប់បង្គាប់យើងទេ វាប្រព្រឹត្តទៅតាមរឿង របស់ វា គឺ អនិច្ចំ ទុក្ខំ អនត្តា ។

សេចក្ដីយល់ថា ខ្លួនយើង និង មិនមែនខ្លួនយើង ឲ្យផលខុសគ្នា យ៉ាងនេះ គឺ អ្នកយល់ថា ខ្លួនយើងមានទុក្ខច្រើន ជាប់ជំពាក់ច្រើន មិនអាច

រំដោះខ្លួនទៅដល់និព្វានបានទេ ។ ឯអ្នកយល់ថា មិនមែនខ្លួនយើង ស្រាលទុក្ខ មិនសូវជាប់ជំពាក់ (អស់ទុក្ខ អស់ជាប់ជំពាក់) អាចរំដោះខ្លួនឲ្យសម្រេច ព្រះនិព្វាន បាន ។

៥-សំណួរ – អ្នកណា និយាយថា ខ្ញុំចង់ទៅបដិបត្តិធម៌ អ្នកនោះខុសធំហើយ ព្រោះ – ១-ខ្ញុំ គ្មានទេ ដូចនេះ ខ្ញុំមិនមែនអ្នកបដិបត្តិធម៌ទេ អ្នកបដិបត្តិធម៌ គឺ ធម៌ ហិរិ ឱត្តប្បៈ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ។ល។ ធម៌បដិបត្តិធម៌ មិនមែនមនុស្សបដិបត្តិធម៌ ឬ ខ្ញុំ បដិបត្តិធម៌ទេ ។ ២-ចង់ ចង់ជាតួលោភៈ យកលោភៈទៅបដិបត្តិធម៌ មិនត្រូវទេ ដូចនេះ មិនបាច់ចង់ទេ ។ ៣-ទៅ ធម៌មាននៅក្នុងខ្លួនយើង ធម៌មាននៅគ្រប់ទីកន្លែង នៅកន្លែងណា បដិបត្តិកន្លែងហ្នឹង ដូចនេះ មិនបាច់ទៅទេ តើទស្សនៈនេះ យ៉ាងម៉េចដែរ ?

ចម្លើយ – ម្នាក់និយាយថា ខ្លួននៅជ្រងោ... អ្នកនេះនៅជើងមេឃខាងកើត ដូចថ្ងៃទើបនឹងរះព្រឹម ៗ ។ ម្នាក់ទៀត និយាយថា ខ្ញុំ មិនចេះបដិបត្តិធម៌ទេ ធម៌បដិបត្តិធម៌... អ្នកនេះ នៅជើងមេឃខាងលិច ដូចថ្ងៃដើរហត់ ១ ថ្ងៃហើយ ជិតលិចព្រិល ៗ ។ ឯម្នាក់ទៀត និយាយថា ខ្ញុំចង់ទៅបដិបត្តិធម៌... អ្នកនេះនៅចន្លោះកណ្តាល ដូចថ្ងៃកំពុងត្រង់ ។ អ្នកនៅកណ្តាល ស្តាប់អ្នកពីរនាក់និយាយ ត្រូវចេះស្តាប់ភាសាគេ បើស្តាប់មិនបានឈឺក្បាល បើស្តាប់មិនយល់ ខូចប្រយោជន៍ ។

យើងគប្បីគិតពិចារណា ធម៌បដិបត្តិធម៌ បើធម៌វានៅតែគ្នាវា វាបដិបត្តិតែគ្នាវា ក៏ស្រេចតែគ្នាវា ។ ប៉ុន្តែ បើធម៌វាជាប់ទាក់ទងជាមួយខ្ញុំ ខ្ញុំត្រូវតែគិត ខ្ញុំត្រូវតែបដិបត្តិ ។ ដើមស្វាយ បើវាដុះខ្លួនវា ផ្លែខ្លួនវា ស្រេចតែវា ។

ប៉ុន្តែ បើវាជាប់ទាក់ទងជាមួយខ្ញុំ គឺខ្ញុំអ្នកដាំវា អ្នកថែរក្សាវា លុះដល់វាផ្លែ វាមិនស៊ីផ្លែរបស់វាទេ គឺខ្ញុំអ្នកស៊ី... បើខ្ញុំដេកហាមាត់ឲ្យស្វាយចូល វាមិនចូលទេ ខ្ញុំត្រូវតែទៅបេះ... ។

ចង់ ជាតួលោភៈ ឬ មិនមែនលោភៈ ស្រេចតែលោកអ្នកប្រាជ្ញចុះ ប៉ុន្តែ មានរឿងដែលយើងគប្បីពិចារណា ព្រះពុទ្ធ បរមគ្រូយើង ព្រះអង្គ ចង់ទៅជាព្រះសព្វញ្ញុពុទ្ធ ព្រះអង្គ ចង់ចម្លងសត្វលោក... ប្រាថ្នាពុទ្ធភូមិ ខំសាងបារមី... បើកុំតែមានចង់ហ្នឹង យើងគ្មានធម៌រៀន គ្មានព្រះពុទ្ធ ថ្វាយបង្គំទេ។

នន្ទ ប្អូនរបស់ព្រះពុទ្ធ បដិបត្តិធម៌ ដើម្បីទេពអប្សរ ប៉ុន្តែ ដោយសារគ្រូពូកែ បំបែររក អរហត្តផល ទាល់តែសម្រេច ។ សូម្បី ចង់ខុសទិសសោះ នៅតែ រកធម៌ឃើញ ។

ព្រះអានន្ទ សម្តែងធម៌ ប្រាប់ភិក្ខុនីថា ម្នាលនាង កាយនេះ កើតពីតណ្ហា ប៉ុន្តែ គេអាស្រ័យតណ្ហា លះតណ្ហា បាន ។ សូម្បីតែ តណ្ហា គេអាចប្រើ រំលត់ទុក្ខបាន ។

បានសេចក្តីថា គ្រូស្នើរ ។ មិនទាន់ចេះប្រើ ចង់ ឬ តណ្ហា ទេ ប៉ុន្តែ បើគ្រូពូកែ គេអាចប្រើ ចង់ ឬ តណ្ហា បាន ។

ពិតមែនហើយ ទីណា ក៏គេ បដិបត្តិធម៌បានដែរ ប៉ុន្តែ មិនមែនប្រែថា កុំទៅ... មិនបាច់ទៅ ដូចនេះទេ ។ ព្រះពុទ្ធ បរមគ្រូយើង បើកុំទៅ នៅបដិបត្តិធម៌ក្នុងវាំង ជាមួយនាងពិម្ពា... មេឃាហើយ... ។ ដោយសារតែព្រះអង្គ ទៅរកធម៌... ទើបបានសម្រេចជាព្រះពុទ្ធ ។ ម្យ៉ាងទៀត ពេលដែលមានភិក្ខុសង្ឃ មកក្រាបថ្វាយបង្គំលាទៅបដិបត្តិធម៌ បើអត់បានប្រយោជន៍ ព្រះពុទ្ធ ហាមឃាត់ហើយ កុំ កុំទៅ បដិបត្តិត្រង់ហ្នឹងទៅ... ប៉ុន្តែ ព្រះអង្គ យល់ឃើញថា មានប្រយោជន៍ ទើបទ្រង់អនុញ្ញាតឲ្យទៅ ។

៦-សំណួរ – គេនិយាយថា អ្នកចំរើន សមថៈវិបស្សនា មិនត្រូវធ្វើការងារ មិនត្រូវនិយាយរឿង ប្រទេស ជាតិ មិនត្រូវធ្វើនយោបាយ តើបានសេចក្តីយ៉ាងម៉េច ?

ចម្លើយ - បានសេចក្តីថា ក្នុងវគ្គបដិបត្តិធម៌ ករណីយកិច្ចសំខាន់ គឺបដិបត្តិ យើងមកទីនេះ មកបដិបត្តិ មិនមែនមកធ្វើការងារ (លើកលែងតែការងារក្នុងកម្មវិធី) មិនមែនមកនិយាយ... មិនមែនមក ធ្វើនយោបាយ ហេតុនេះ អ្នកសមថៈវិបស្សនា គ្រប់រូប ត្រូវគោរពកម្មវិធី និង បដិបត្តិ ឲ្យបានត្រឹមត្រូវ ដើម្បីកុំឲ្យខូចប្រយោជន៍ខ្លួន ខូចប្រយោជន៍អ្នកដទៃ និង ខូចប្រយោជន៍ទីកន្លែង ។

៧-សំណួរ – គេនិយាយបន្តទៀតថា មិនមែនតែក្នុងវគ្គបដិបត្តិធម៌ទេ តទៅថ្ងៃមុខទៀត អ្នកចំរើន សមថៈ វិបស្សនា ក៏មិនត្រូវធ្វើការងារ មិនត្រូវនិយាយរឿងប្រទេស ជាតិ មិនត្រូវធ្វើនយោបាយដែរ ត្រូវតែខំបដិបត្តិធម៌ប៉ុណ្ណោះ អីចឹងមែនឬ ?

ចម្លើយ – គេថាហ្នឹង ១០ គេ ១០ ថា សូម្បីថ្នាក់គ្រូ ក៏ ១០ គ្រូ ១០ថា ដែរ ដូចនេះ យើងមិនចេះតែជឿគេទេ ត្រូវយកបញ្ញាមកពិចារណារកហេតុផលផង ។ បើគេចូលមកបដិបត្តិធម៌ ធ្វើ សមថៈវិបស្សនា យើងចងដៃគេជាប់ មិនឲ្យគេធ្វើការងារ តើបានប្រយោជន៍អ្វី ? បានប្រយោជន៍អ្វីដល់គេ ដល់គ្រួសារគេ ? បានប្រយោជន៍អ្វីដល់ជាតិ ? បានប្រយោជន៍អ្វីដល់សាសនា ? នរណា ហ៊ានមកធ្វើ សមថៈ វិបស្សនា ទៀត ? គោលបំណងសំខាន់នៃការបដិបត្តិធម៌ គឺការកើតប្រយោជន៍ និង សេចក្តីសុខ-ចំរើន ទាំងអស់គ្នា តាំងពីបច្ចុប្បន្ន រហូតដល់ បរលោក និង ព្រះនិព្វាន ជាបរិយោសាន ។

# ចង់បានក្តីសុខ

ចង់បានក្តីសុខ ឈប់គិតស្រុកទេស　　នាំគ្នាប្រហែសហើយថាបានធម៌
សុខចិត្តឲ្យខ្មាំងចូលមកឈ្លានរ　　យកមុខរបរក៏មិនខ្វល់ឡើយ ។
ស្រវឹងក្តីសុខនាំគ្នាសប្បាយ　　សើចលេងក្អាកក្អាយច្រៀងរាំព្រងើយ
បានសុខប៉ុណ្ណោះថាប្រសើរហើយ　　បងប្អូនខ្មែរអើយឈប់គិតគួរទៅ ។
ខ្មាំងឲ្យខ្មែរសុខពិតមែនឬទេ　　ម៉េចមិនគ្នាន់គ្នេរគិតគូរឲ្យជ្រៅ
យើងនឹងធ្លាក់ខ្លួនខ្ញុំគេឥឡូវ　　ថោកទាបពេកក្រូវគួរឲ្យអាម៉ាស់ ។
ចង់បានក្តីសុខមិនហ៊ាននិយាយ　　ការពិតទាំងឡាយឲ្យឃើញជាក់ច្បាស់
សុខចិត្តឥតខ្វល់ហ្នឹងឬល្អណាស់　　គួរឲ្យអៀនខ្មាសសព្វសត្វទាំងឡាយ ។
បងប្អូនប្រុសស្រីយើងខ្មែរអង្គរ　　កុំនៅស្ងៀមឈរ រំពឹងឲ្យឆ្ងាយ
សាមគ្គីធ្លុងមួយគិតជួយដោះស្រាយ　　កំចាត់កំចាយសត្រូវឈ្លានពាន ។
សម័យឧដុង្គខ្មែរប្រុងស្មារតី　　ទាំងប្រុសទាំងស្រីចិត្តខ្លាំងក្លាហាន
ក្រោកស៊ូប្រយុទ្ធដេញចោរសាមាន្យ　　ឲ្យអន្តរធានចេញពីស្រុកខ្មែរ ។
សម័យភ្នំពេញយើងវិញយ៉ាងម៉េច　　គិតឲ្យសម្រេចផលដូចគេដែរ
បំណាច់យើងកើតមកជាកូនខ្មែរ　　ពួជខ្លាំងពូកែកុំធ្វើខ្ញុំគេ ។
គ្រហស្ថព្រះសង្ឃស្មោះត្រង់ប្រញាប់　　រួមគ្នាឲ្យឆាប់កុំនៅទំនេរ
ដេញខ្មាំងគ្រប់ទិសឥតមានសល់ទេ　　តាមយើងគ្នាន់គ្នេរបានព្រមព្រៀងគ្នា។
ពួកខ្មាំងអប្រិយចង្រៃអស់ហើយ　　យើងបានធូរស្បើយសាងកម្ពុជា
បានសុខចំរើនកើនវឌ្ឍនា　　ខ្មែរកម្ពុជាសម្បូរសប្បាយ ៕ចប់